ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់ អគ្គនាយកដ្ឋានពន្ធដារ

THE AMENDMENT OF THE INCOME TAX SALARIES OF THE GENERAL DEPARTMENT OF TAXATION.

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់ អគ្គនាយកដ្ឋានពន្ធដារ

THE AMENDMENT OF THE INCOME TAX SALARIES OF THE GENERAL DEPARTMENT OF TAXATION.

គ្រូណែនាំ៖ សុខ ផានី

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទៈ ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់**

**អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

អ្នកគ្រូណែនាំ

សុខ ផានី

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក

មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង

មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេសក្រុមយើងខ្ញុំបានយល់ច្បាស់ថា ជំនាញគណនេយ្យ គឺជាជំនាញមួយដែលមានសារៈសំខាន់ សម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តន៍កិច្ចការគណនេយ្យដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិត កាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សា ក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤ ។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការវិសោធនកម្មពន្ធលើប្រាក់បៀវត្ស។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះឡើង នឹងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ឆុន ស្រីពេជ

ID: B22/1808



ហាក់ សុផល

ID: B22/221



ហេង រក្សា

ID: B22/681



សុន្ធី ស្រីអូន

ID: B22/1029



ខឹម ស្រីអូន

ID: B22/1103

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់ក្រុមយើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **សុខ ផានី** ជាអ្នកគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងបុគ្គលិក នៃសាកលវិទ្យាល័យវ៉ាន់ដា ទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី ″ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ″ នេះគឺពិតជាស្នាដៃមួយរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ..៨កើតខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ថ្ងៃទី.២៩. ខែតុលា ឆ្នាំ២០២៥
**ហត្ថលេខាតំណាងក្រុម**



ធុន ស្រីពេជ

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

អគ្គនាយកដ្ឋានពន្ធដារ គឺជាអង្គភាពមួយសម្រាប់ប្រមូលពន្ធគ្រប់ប្រភេទជូនរដ្ឋ ហើយត្រូវបានកើតឡើងដំបូងនៅឆ្នាំ១៩៥៣ ប៉ុន្តែត្រូវបានគេលុបបំបាត់ចោលទាំងស្រុងដោយសាររបបប៉ុលពត នៅឆ្នាំ ១៩៧៥ ដល់ ១៩៧៩។ បន្ទាប់មកនៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៨ ដោយយោងតាមអនុក្រឹតលេខ៣១១ អនក្រម.ក បាន ដំឡើងនាយកដ្ឋានពន្ធដារទៅជាអគ្គនាយកដ្ឋានពន្ធដារ សស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានសាខានៅតាមបណ្តា ខេត្ត-ក្រុង ព្រមទាំងស្រុក-ខណ្ឌ និងបានបង្កើតទីស្នាក់ការ ពន្ធដារបន្ថែមទៀតផងដែរ។ ចំណូលដែលបានមកពីការដកហូតពន្ធត្រូវបានយកទៅអភិវឌ្ឍន៍ប្រទេសជាតិ ដូចជា ផ្គត់ផ្គង់ទៅលើ សាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ និងប្រាក់ខែមន្ត្រីរាជការដែលស្ថិតនៅក្រោមស្ថាប័នរដ្ឋ ។ ចំណូលពន្ធរយៈពេល១០ឆ្នាំបន្តបន្ទាប់មកយើងសង្កេតឃើញថា ចំណូលពន្ធមានការកើនឡើងជាលំដាប់ជារៀងរាល់ឆ្នាំ។

ការធ្វើវិសោធនកម្មលើពន្ធប្រាក់បៀវត្សនៅកម្ពុជា បានឆ្លងកាត់ការផ្លាស់ប្តូរជាច្រើនក្នុងអំឡុងពេលកន្លងមក ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ការផ្លាស់ប្តូរទាំងនេះ មានគោលបំណងធានាថា ប្រព័ន្ធពន្ធប្រាក់បៀវត្សមានភាពត្រឹមត្រូវ និងសមស្របសម្រាប់ប្រជាជនកម្ពុជា។ ក្នុងអំឡុងពេលចុងក្រោយនេះ ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សបានផ្តោតលើការកែប្រែអត្រាពន្ធ និងកម្រិតប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ។ ការផ្លាស់ប្តូរទាំងនេះ មានគោលបំណងបន្ធូរបន្ថយបន្ទុកពន្ធលើបុគ្គលដែលមានប្រាក់បៀវត្សទាប និងធានាថា ការបង់ពន្ធមានភាពត្រឹមត្រូវសម្រាប់បុគ្គលដែលមានប្រាក់បៀវត្សខ្ពស់។ អគ្គនាយកដ្ឋានពន្ធដារ គឺជាអង្គភាពមួយសម្រាប់ប្រមូលពន្ធគ្រប់ប្រភេទជូនរដ្ឋ ហើយត្រូវបានកើត ឡើងដំបូងនៅឆ្នាំ១៩៥៣ ប៉ុន្តែ ត្រូវបានគេលុបបំបាត់ចោលទាំងស្រុងដោយសាររបបប៉ុលពត នៅឆ្នាំ១៩៧៥ ដល់ ១៩៧៩។ បន្ទាប់មកនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ដោយយោងតាមអនុក្រឹតលេខ៣១១ អនក្រមក បាន ដំឡើងនាយកដ្ឋានពន្ធដារទៅជាអគ្គនាយកដ្ឋានពន្ធដារ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានសាខានៅតាមបណ្តាខេត្ត-ក្រុង ព្រមទាំងស្រុក-ខណ្ឌ និងបានបង្កើតទីស្នាក់ការពន្ធដារបន្ថែមទៀតផងដែរ។ ចំណូលដែលបានមកពីការដកហូតពន្ធត្រូវបានយកទៅអភិវឌ្ឍន៍ប្រទេសជាតិ ដូចជា ផ្គត់ផ្គង់ទៅលើ សាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ និងប្រាក់ខែមន្ត្រីរាជការដែលស្ថិតនៅក្រោមស្ថាប័នរដ្ឋ។ ចំណូលពន្ធរយៈពេល១០ឆ្នាំបន្តបន្ទាប់មកយើងសង្កេតឃើញថា ចំណូលពន្ធមានការកើនឡើងជាលំដាប់ជារៀងរាល់ឆ្នាំ។

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "**ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ**" ក្រុមនាងខ្ញុំសន្និដ្ឋានបានថា ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សពិតជាមានសារៈសំខាន់ណាស់ចំពោះប្រជាពលរដ្ឋ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ការជួយបង្កើនចំណូលថវិកាជាតិ និងចូលរួមចំណែកកាត់បន្ថយឱនភាពថវិកា។ ពន្ធលើប្រាក់បៀវត្ស ជាផ្នែកមួយនៃប្រាក់ចំណូលរបស់រដ្ឋ ដែលអាចប្រើប្រាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាកម្មសង្គម ដូចជា វិស័យសុខាភិបាល ការអប់រំ និងកម្រិតសេវាកម្មផ្សេងៗ។ ពន្ធ ដែលត្រូវបង់សម្រាប់ប្រាក់បៀវត្សនឹងជួយផ្គត់ផ្គង់សេវាកម្មសាធារណៈដូចជា សាលារៀន មន្ទីរពេទ្យ មន្ត្រីរាជការស៊ីវិល ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កងកម្លាំងប្រដាប់អាវុធ

ដែលជាបន្ទុករដ្ឋបាល ការពារសន្តិសុខសណ្តាប់ធ្នាប់ ការពារអធិបតេយ្យភាព និងប្រទេសបូរណភាពទឹកដីរបស់ប្រទេសជាតិ។ យ៉ាងណាមិញ យើងក៏សង្កេតឃើញថាប្រជាពលរដ្ឋពួកគាត់ក៏មានការយល់ដឹង និងបានចូលរួមបង់ពន្ធកាន់តែច្រើនជាងមុន។ ហេតុដូច្នេះពួកយើងក៏សង្ឃឹមថា ការខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងអគ្គនាយកដ្ឋានពន្ធដារនិងមានការរីកចម្រើនទៅមុខជាលំដាប់។

# មាតិកា


ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័នក្រុម ........ ii

សេចក្ដីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ........ v

មាតិកា ........ vii

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

  ១.៤.១ ទំហំដែនកំណត់ ........ ២

  ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

  ១.៥.១ ការប្រមូលទិន្នន័យបន្ទាប់ ........ ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី២
## ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស

២.១ លក្ខណៈទូទៅនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស ........ ៥

  ២.១.១ និយមន័យពន្ធ ........ ៥

  ២.១.២ ប្រវត្តិពន្ធ ........ ៦

២.២ គោលបំណងនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស ........ ៦

  ២.២.១ និយមន័យវិសោធនកម្ម ........ ៦

  ២.២.២ ប្រវត្តិនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស ........ ៧

  ២.២.៣ ប្រភេទពន្ធអាករ ........ ៧

២.៣ ប្រាក់ពន្ធដែលបានប្រមូលបានពីពន្ធលើប្រាក់បៀវត្សបានផ្ដល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ ... ៨

  ២.៣.១ និយមន័យពន្ធលើប្រាក់បៀវត្ស ........ ៨

  ២.៣.២ ប្រវត្តិពន្ធលើប្រាក់បៀវត្ស ........ ៨

២.៣.៣ ការគណនាពន្ធលើប្រាក់បៀវត្ស........................................................................ ៩
២.៣.៤ និយមន័យសេដ្ឋកិច្ច.........................................................................................១១
២.៣.៥ ប្រវត្តិសេដ្ឋកិច្ច...............................................................................................១១

## ជំពូកទី៣
## ដំណើរការនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ........................................................... ១៣
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ.......................................................................... ១៣
៣.១.២ ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់អគ្គនាយកដ្ឋានពន្ធដារ ..........................១៤
ក. ចក្ខុវិស័យ ..........................................................................................................១៤
ខ. បេសកកម្ម...........................................................................................................១៥
គ. គោលដៅ ............................................................................................................១៥
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចគណៈគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ ១៧
ក. រចនាសម្ព័ន្ធគ្រប់គ្រង.......................................................................................... ១៧
ខ. តួនាទី និងភារកិច្ចគណៈគ្រប់គ្រង........................................................................១៨
៣.២ ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ ..................................១៩
៣.២.១ គោលបំណងនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ ... ១៩
៣.២.២ ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ .................... ២០
៣.៣ ប្រាក់ពន្ធដែលប្រមូលបានពីពន្ធលើប្រាក់បៀវត្សបានផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ ..... ២៧
៣.៣.១ អត្ថប្រយោជន៍ពីប្រាក់ពន្ធដែលប្រមូលបានពីពន្ធលើប្រាក់បៀវត្ស........................ ២៧

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង......................................................................................... ២៩
៤.២ ការវិភាគលើចំណុចខ្សោយ ..................................................................................... ៣០

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ...................................................................................................... ៣១
៥.២ ការផ្តល់អនុសាសន៍ ................................................................................................... ៣១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការប្រមូលពន្ធ គឺមានតាំងពីសម័យបុរាណមកម្ល៉េះដោយគេប្រើប្រព័ន្ធមណ្ឌលរដ្ឋបាលមួយ ដើម្បីផ្គត់ផ្គង់រាជធានី ហើយប្រព័ន្ធពន្ធដារជួយឱ្យចក្រភពខ្មែរមានភាពថ្កុំថ្កើង និងរីកចម្រើនខ្លាំង។ បើនិយាយឱ្យចំទៅការបង់ពន្ធមានប្រវត្តិដ៏ចំណាស់រាប់ពាន់ឆ្នាំមកហើយ ពោលគឺចាប់តាំងពីការបង្កើតរដ្ឋដំបូងមកម្ល៉េះ។ ការបង់ពន្ធ គឺជាមូលដ្ឋានគ្រឹះនៃកាបង្កើតរដ្ឋដំបូង គឺរដ្ឋមានកាតព្វកិច្ចរក្សាសណ្តាប់ធ្នាប់ និងការពារសន្តិសុខរបស់ប្រជាពលរដ្ឋ ព្រមទាំងធានានូវសេវាសាធារណៈសម្រាប់សហគមន៍ ចំណែកពលរដ្ឋវិញមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។

ជាការពិតណាស់ការបង់ពន្ធ ពីសំណាក់ប្រជាពលរដ្ឋពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកៀរគរចំណូលសម្រាប់ប្រទេសជាតិដើម្បីឆ្លើយតបទៅនឹងចំណាយទូទាំងប្រទេស។ ការបង់ពន្ធពីសំណាក់ប្រជាពលរដ្ឋ គឺជាផ្នែកមួយដ៏សំខាន់ ដើម្បីឱ្យរាជរដ្ឋាភិបាលបានចំណូលក្នុងការទូទាត់ចំណាយលើសេវាសាធារណៈ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រទេសឱ្យកាន់តែរីកចម្រើន។ ក្នុងការលើកស្ទួយសេដ្ឋកិច្ចឱ្យមានកំណើនខ្ពស់ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកាន់តែត្រូវបានលើកកម្ពស់យ៉ាងខ្លាំងក្លា និងអត្រាភាពក្រីក្រត្រូវបានកាត់បន្ថយ។ ប្រទេសកម្ពុជាមានការអភិវឌ្ឍគ្រប់វិស័យ បើក្រឡេកមកមើលវិស័យពន្ធដារវិញបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេស។ ទោះជាយ៉ាងណាក៏ដោយ ការដកហូតពន្ធតែងតែបង្កការឈឺចាប់ដល់អ្នកជាប់ពន្ធ ព្រោះការដកហូតពន្ធនេះ គឺត្រូវបានកាត់បន្ថយនូវប្រាក់បៀវត្ស ដែលជាប្រាក់ចំណូលផ្ទាល់របស់និយោជិតតែម្តង។ ដូច្នេះហើយ បានជាការប្រមូលពន្ធលើប្រាក់បៀវត្ស ត្រូវធ្វើឡើងតាមរយៈគ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុក និងបង់ពន្ធលើប្រាក់បៀវត្សត្រូវប្រមូលឡើងតាមរបៀបកាត់ទុកជាមុនជារៀងរាល់ខែដោយនិយោជកនៅរាល់ពេលបើកប្រាក់បៀវត្ស។

អគ្គនាយកដ្ឋានពន្ធដារកម្ពុជាតែងតែយកចិត្តទុកដាក់ជួយកែប្រែច្បាប់ផ្សេងៗ ដើម្បីជួយសម្រួលការរស់នៅឱ្យកាន់តែមានភាពប្រសើរឡើង ដើម្បីឱ្យពលរដ្ឋមានទឹកចិត្ត និងខិតខំប្រឹងប្រែងក្នុងការបង់ពន្ធយ៉ាងមានស្មោះភាព។ រាជរដ្ឋាភិបាលចាំបាច់ធ្វើការឆ្លុះបញ្ចាំង និងបម្លែងចំណូលបានមកពីពន្ធទៅជាវឌ្ឍនៈភាព ឬសមិទ្ធិផលនៃកាតព្វកិច្ចការងាររបស់ខ្លួនប្រកបដោយ សមភាព គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព ស័ក្កសិទ្ធភាព ទាំងនេះជាតម្លៃស្នូលនៃការតបស្នងដោយសាមគ្គីភាពដែលមិនអាចខ្វះបានរវាងពលរដ្ឋ និងរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍រដ្ឋឱ្យមានភាពរីកចម្រើនជឿនលឿនគ្រប់វិស័យ។ ទន្ទឹមនិងការរីកចម្រើននៃសេដ្ឋកិច្ចជាតិជាហេតុធ្វើឱ្យអគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែសម្រួល និងធ្វើវិសោធនទៅលើពន្ធមួយចំនួន។ ដូច្នេះហើយទើបក្រុមយើងខ្ញុំលើកយកប្រធានបទ "**ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ**" ដើម្បីធ្វើការស្រាវជ្រាវ និងបកស្រាយ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងដឹងហើយថា ពន្ធដារនៅកម្ពុជាជាប្រធានបទមួយដែលទទួលបានការចាប់អារម្មណ៍ពីប្រជាពលរដ្ឋ ជាពិសេសបញ្ហាពន្ធលើប្រាក់បៀវត្ស។ ដោយមើលឃើញពីបញ្ហាទាំងអស់ហ្នឹងហើយទើបក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវពីបញ្ហាពន្ធលើប្រាក់បៀវត្សដោយមានសំណួរចោទសួរថា៖

១.តើអគ្គនាយកដ្ឋានពន្ធដារធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សក្នុងគោលបំណងអ្វី?

២.តើប្រាក់ពន្ធដែលប្រមូលបានពីពន្ធលើប្រាក់បៀវត្សបានផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់សេដ្ឋកិច្ចជាតិ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីពន្ធលើប្រាក់បៀវត្សក៏ដូចជាការបម្រែបម្រួលពន្ធលើប្រាក់បៀវត្សនៅក្នុងប្រទេសកម្ពុជាដែលមានគោលបំណងស្វែងយល់អំពី៖

- យល់ដឹងអំពីអត្រាជាប់ពន្ធលើប្រាក់បៀវត្ស
- ការគណនាមូលដ្ឋានគិតពន្ធលើបុគ្គលដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស
- ការបង្កើតការយល់ដឹង និងការផ្លាស់ប្តូរនៃពន្ធលើប្រាក់បៀវត្ស
- ការប៉ាន់ស្មានអភិវឌ្ឍន៍នាពេលអនាគត
- ស្វែងយល់ពីបម្រែបម្រួលអត្រាជាប់ពន្ធតាមថ្នាក់ឱ្យកាន់តែច្បាស់
- ដើម្បីវិភាគពីប្រសិទ្ធភាពនៃប្រព័ន្ធពន្ធបច្ចុប្បន្នពិនិត្យថាការច្បាប់ពន្ធលើប្រាក់បៀវត្សបច្ចុប្បន្នមានភាពសមរម្យ ឬទេនៅក្នុងការប្រមូលចំណូល និងការគ្រប់គ្រងពន្ធ
- ដើម្បីស្វែងយល់ពីផលប៉ះពាល់ដល់អ្នកធ្វើការ និងសហគ្រាស ការស្រាវជ្រាវនេះស្វែងយល់ថា វិសោធនកម្មពន្ធអាចប៉ះពាល់ដល់ថ្នាក់ជាងទាប បណ្តាសហគ្រាស និងសេដ្ឋកិច្ចជាតិយ៉ាងដូចម្តេច
- ដើម្បីផ្តល់យោបល់ប្រសើរនៃនីតិវិធីពន្ធ ជួយផ្តល់មតិយោបល់ ឬផ្តល់អនុសាសន៍ដល់រដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធភាព និងភាពស្មើរគ្នានៃការបង់ពន្ធលើប្រាក់បៀវត្ស
- ដើម្បីពង្រឹងភាពត្រឹមត្រូវនៃការបង់ពន្ធ ពិនិត្យពីភាពអយុត្តិធម៌ ឬអសមភាពក្នុងការទាមទារពន្ធលើប្រាក់បៀវត្ស និងរកវិធីដោះស្រាយ
- ដើម្បីលើកស្ទួយការប្រមូលចំណូលរដ្ឋ ស្វែងរកបៀបធ្វើអោយការធ្វើវិសោធនកម្មពន្ធអាចជួយបង្កើនប្រាក់ចំណូលរដ្ឋ ដោយមិនធ្វើអោយមានផលប៉ះពាល់ខ្លាំងដល់ប្រជាពលរដ្ឋ។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ដោយសារច្បាប់និងបទប្បញ្ញត្តិពន្ធដារមានច្រើនទៅតាមប្រភេទពន្ធនីមួយៗ ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវ ក្រុមយើងខ្ញុំសុំផ្តោតសំខាន់ទៅលើការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ និងអត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ចជាតិ ដែលប្រមូលបានពីប្រាក់ពន្ធលើប្រាក់បៀវត្ស។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺជាការសិក្សាទៅលើការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារត្រឹមឆ្នាំ២០២២ តែប៉ុណ្ណោះ។

# ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

## ១.៥.១ ការប្រមូលទិន្នន័យបន្ទាប់

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យដែល ជាវិធីសាស្ត្រស្រាវជ្រាវក្នុងការប្រមូលឯកសារ និងនិទ្ទន័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ តាមរយៈគេហទំព័រ ច្បាប់ស្ដីពីសារពើពន្ធ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សៀវភៅច្បាប់ពន្ធដារកម្ពុជា ទស្សនាវដ្ដីវិទ្យាសាស្ត្រដែលមាននៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យវ៉ាន់ដា និងសារណានិស្សិតជំនាន់មុន ។

សម្រាប់សំណួរស្រាវជ្រាវទី១ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ការស្រាវជ្រាវនេះធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យដែលមានស្រាប់ ដូចជា តាមរយៈគេហទំព័រ ច្បាប់ស្ដីពីសារពើពន្ធ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការផ្ដល់អនុសាស្ត្រន៍ និងការណែនាំពីសាស្ត្រាចារ្យនៅសាកលវិទ្យាល័យវ៉ាន់ដា តាមប្រព័ន្ធអ៊ិនធឺណេត និងឯកសារផ្សេងៗដែលស្រាវជ្រាវពីបណ្ណាល័យនៃសាកលវិទ្យាល័យវ៉ាន់ដា រួមបញ្ចូលជាមួយនិងចំណេះដឹងដែលធ្លាប់បានសិក្សា ដើម្បីយល់ដឹងអំពីការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ និងភាពខុសគ្នាពីជំណាក់កាលមួយទៅជំណាក់កាលមួយ។

សម្រាប់សំណួរស្រាវជ្រាវទី២ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ការស្រាវជ្រាវនេះធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យដែលមានស្រាប់ ដូចជា ការពិភាក្សាយោបល់ពីមិត្តរួមក្រុមផ្ទាល់ និងគ្រូណែនាំ បទប្បញ្ញត្តិនានាដែលទាក់ទងជាមួយការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជាប្រយោជន៍ក្នុងការស្រាវជ្រាវ ព្រមទាំងការយល់ដឹងឱ្យកាន់តែច្បាស់បន្ថែមទៀត ។

# ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺជាការបន្ថែមនូវចំណេះដឹងមួយបន្ថែមទៀតក្រៅពីការសិក្សានៅក្នុងថ្នាក់ជាមួយលោកគ្រូ អ្នកគ្រូ ហើយក្រុមយើងខ្ញុំនឹងសង្ឃឹមថាស្នាដៃមួយនេះបានផ្ដល់ប្រយោជន៍ និងចំណេះដឹងដល់អ្នកអាន និងអ្នកស្ដាប់ក្នុងការក្រេបជញ្ជក់រាល់ខ្លឹមសារនៃប្រធានបទខាងលើនេះដែលបានបង្ហាញពីសារៈសំខាន់ជាច្រើនដូចជា៖

**+ ចំពោះនិស្សិតស្រាវជ្រាវ**

- យល់ដឹងឱ្យកាន់តែច្បាស់ពីប្រភេទពន្ធដារនៅកម្ពុជា ជាពិសេសពន្ធលើប្រាក់បៀវត្ស
- ទទួលបានបទពិសោធន៍ក្នុងកាលវិភាគ ក៏ដូចជាការដោះស្រាយបញ្ហានានា
- មានទំនាក់ទំនងល្អក្នុងការសហការគ្នាជាក្រុម និងការស្វ័យសិក្សា
- ស្គាល់ពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ និងប្រវត្តិពន្ធដារនៅកម្ពុជា
- យល់ដឹងកាន់តែច្បាស់អំពីការគណនាប្រាក់បៀវត្សជាប់ពន្ធ
- យល់ដឹងពីកាធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សលក្ខណៈខុសប្លែកគ្នា និងអត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច
- បង្កើនចំណេះដឹង និងជំនាញវិជ្ជាជីវៈក្នុងដែនកំណត់
- បង្កើតអាជីព និងភាពជាអ្នកជំនាញក្នុងវិស័យណាមួយ
- រចនា និងអភិវឌ្ឍន៍គំនិតច្នៃប្រឌិត និងវិធិសាស្ត្រថ្មីៗ

- បង្ហាញសមត្ថភាពនៅក្នុងបរិបទវិទ្យាសាស្ត្រសង្គម ។

**+ ចំពោះអគ្គនាយកដ្ឋានពន្ធដារ**

- ប្រើស្រាវជ្រាវក្នុងការកំណត់គោលនយោបាយ ដើម្បីធានាបាននូវភាពតុល្យភាព និងប្រសិទ្ធភាពក្នុងការបង់ពន្ធ
- គាំទ្រការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងពន្ធ ដោយផ្អែកលើអានុភាពនៃទិន្នន័យ និងអាកប្បកិរិយាពិតប្រាកដរបស់អ្នកបង់ពន្ធ
- ជួយកំណត់អត្រាពន្ធឱ្យសមរម្យ ទៅនឹងស្ថានភាពសេដ្ឋកិច្ច និងបរិបទសង្គម
- ជួយសម្រេចគោលបំណងយុទ្ធសាស្ត្រ ដោយផ្អែកលើទិន្នន័យជាក់ស្តែង
- ជួយបង្កើនប្រាក់ចំណូលរដ្ឋ តាមរយៈការសម្រេចយុទ្ធសាស្ត្រដែលមានផ្អែកលើព័ត៌មានស្រាវជ្រាវ
- បង្កើនប្រសិទ្ធភាពនៃការអនុវត្តនីតិវិធី និងសេវាកម្ម។

**+ ចំពោះសង្គមជាតិ**

- ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម
- ជួយដោះស្រាយបញ្ហាសង្គម ដូចជាសុខភាព បរិស្ថាន ការអប់រំ
- ចិញ្ចឹមវប្បធម៌នៃការសួរចម្លើយ និងអភិវឌ្ឍនូវវិជ្ជានុបទ្យ
- បង្កើនភាពយល់ដឹង និងចូលរួមរបស់ប្រជាជន ក្នុងការអភិវឌ្ឍជាតិ
- ជាឧបករណ៍សំខាន់សម្រាប់ការគ្រប់គ្រង និងបង្កើតគោលនយោបាយជាតិ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវធ្វើឡើង ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់នូវចំណុចនីមួយៗ ដោយការរួមបញ្ចូលចំណុចដូចជា៖ សេចក្តីផ្តើមនៃការស្រាវជ្រាវ រំលឹកទ្រឹស្តី លទ្ធផលនៃការស្រាវជ្រាវ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ជាដើម។ ក្រោយពីបានស្រាវជ្រាវមកក្រុមនាងខ្ញុំបានបែងចែកជា ៥ ជំពូកដូចជា៖

**ជំពូកទី១៖ សេចក្តីផ្តើម** បង្ហាញពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ដែនកំណត់ វិសាលភាព វិធីសាស្ត្រ សារៈសំខាន់ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖ ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស** ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស លក្ខណៈទូទៅ និយមន័យ ប្រវត្តពន្ធ គោលបំណង និងប្រវត្តិនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស ប្រភេទពន្ធអាករអត្ថប្រយោជន៍ដែលប្រមូលបានពីពន្ធប្រាក់បៀវត្ស ការគណនាពន្ធលើប្រាក់បៀវត្ស។

**ជំពូកទី៣៖ ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ** ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ និងបកស្រាយទាក់ទងនិងសំណួរដែលបានចោទសួរ។

**ជំពូកទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** វិភាគ និងស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍** សន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានស្រាវជ្រាវ និងការផ្តល់អនុសាសន៍ដើម្បីកែលម្អនូវចំណុចខ្វះខាត។

# ជំពូកទី២

# ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស

## ២.១ លក្ខណៈទូទៅនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស

### ២.១.១ និយមន័យពន្ធ

**ពន្ធ (Taxation)** គឺជាកាតព្វកិច្ចបង់ជាប្រាក់ ឬវត្ថុរបស់អ្នកជាប់ពន្ធទៅរដ្ឋាភិបាល ហើយអ្នកជាប់ពន្ធទាំងនោះទទួលតម្លៃតបស្នងពីរដ្ឋាភិបាលវិញតាមរយៈទំនិញ និងសេវាសាធារណៈ។

**ពន្ធ (Taxation)** គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិកាជាតិ។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។

**ពន្ធ (Taxation)** ជាឧបករណ៍របស់រដ្ឋាភិបាលដែលបានបង្កើតឡើង ដើម្បីកៀរគរចំណូលចូលថវិកាជាតិសម្រាប់ចំណាយសាធារណៈ។

**ពន្ធ (Taxation)** គឺជាកាតព្វកិច្ចផ្ទាល់របស់អ្នកបង់ពន្ធ មានន័យថា អ្នកជាប់ពន្ធត្រូវបង់ពន្ធទៅឱ្យរដ្ឋផ្ទាល់ ឬតាមភ្នាក់ងារពន្ធដារ ហើយពន្ធជាកាតព្វកិច្ចរបស់បុគ្គលគ្រប់រូបដែលអ្នកជាប់ពន្ធមិនកំណត់ថាទាល់តែជាបុគ្គលដែលបានចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូចឬមធ្យម ឬធំទេ។

**ពន្ធ (Taxation)** សំដៅដល់ ពន្ធអាករ (ពន្ធផ្ទាល់ និងពន្ធប្រយោល)[1] ។

**ពន្ធ (Taxation)** គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ និងជាកាតព្វកិច្ចរបស់គ្រប់សមាសភាពដែលកំណត់ដោយច្បាប់។យោងតាមច្បាប់ស្តីពីពន្ធដារឆ្នាំ ១៩៩៧ ពន្ធសំដៅដល់ពន្ធផ្ទាល់ដែលជាប្រភេទពន្ធប្រមូលយកដោយផ្ទាល់ ពីអ្នកជាប់ពន្ធ(Taxpayer) ក្រៅពីពន្ធគយ ឬអាករដែលសំដៅដល់ពន្ធប្រយោលដែលជាប្រភេទនៃការប្រមូលពន្ធដោយប្រយោល(មិនបានប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ)។ ការប្រមូលពន្ធនេះគឺជាការយកតាមតម្លៃ ទំនិញ ឬសេវា ហើយអ្នកជាប់ពន្ធគឺជាអ្នកប្រើប្រាស់ចុងក្រោយ[2]។

**ពន្ធ (Taxation)** នៅក្នុងច្បាប់ស្តីពីសារពើពន្ធ ពាក្យ "**ពន្ធ**" សំដៅដល់ពន្ធ និងអាករទាំងឡាយ។ ពាក្យថា "**ពន្ធ**" គឺសំដៅដល់ការកំណត់បន្ទុកហិរញ្ញវត្ថុជាកំហិតដោយរដ្ឋាភិបាលចំពោះអ្នកជាប់ពន្ធ (រូបវន្តបុគ្គល ឬនីតិបុគ្គល) សម្រាប់ទ្រទ្រង់ចំណាយរបស់រដ្ឋាភិបាល និងចំណាយលើវិស័យសាធារណៈជាច្រើនប្រភេទទៀត[3]។

**ពន្ធ (Taxation)** គឺជារូបភាពនៃការបែងចែកឡើងវិញ នូវចំណូលជាតិ ដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូលមួយផ្នែកពីគ្រប់សមាសភាពសេដ្ឋកិច្ច ដូចជា ក្រុមហ៊ុន សហគ្រាស អាជីវកម្ម សិប្បកម្ម ពាណិជ្ជកម្ម... និង ប្រជាពលរដ្ឋ ដើម្បីបម្រើឱ្យតម្រូវការរួមរបស់សង្គមជាតិទាំងមូល។

**ពន្ធ (Taxation)** គឺជារូបធាតុនៃការប្រមូលចំណូលមួយដែលផ្សារភ្ជាប់ជាមួយ និងសិទ្ធអំណាចនយោបាយរបស់រដ្ឋាភិបាលដែលក្រឹត្យច្បាប់ជាកំណត់ ។

[1] វិទ្យាស្ថានវ៉ាន់ដា. (២០២៤). *ច្បាប់ពន្ធដារកម្ពុជា*. បោះពុម្ពលើកទី១. ទំព័រទី២. ភ្នំពេញ។

[2] BiZKHMER. ប៉ុម ទូច. (2019, October 08). *តើពន្ធគឺជាអ្វី?* Retrieved from https://bizkhmer.com/articles/41290# (Accessed 12.03.25)

[3] អគ្គនាយកដ្ឋានពន្ធដារ. (២០២២). *សន្ទានុក្រមពន្ធដារ*. បោះពុម្ពលើកទី១ ទំព័រទី១៣២. ភ្នំពេញ។

**ពន្ធ (Taxation)** គឺជាការបង់វិភាគទាននូវកាតព្វកិច្ច របស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និងនិតិបុគ្គលជូនរដ្ឋាភិបាលដែលមានច្បាប់កំណត់[4]។

**២.១.២ ប្រវត្តិពន្ធ**

ប្រភពដើមនៃការជាប់ពន្ធដំបូង គឺមានដើមកំណើតមកពីប្រទេសអេហ្ស៊ីបប្រហែល ៣០០០ មុនគ.ស ទោះបីជាការយកពន្ធមានប្រវត្តិយូរអង្វែងក៏ដោយ វាបានដើរតួតិចតួចក្នុងសម័យបុរាណ។ ពន្ធលើការប្រកបអាជីវកម្មត្រូវបានគិតនៅក្រិច និងរ៉ូម។ ពន្ធគយ ពន្ធលើទំនិញនាំចូល ជាញឹកញាប់មានសារៈសំខានគួរឱ្យកត់សម្គាល់ជាងពន្ធអាករក្នុងស្រុករហូតមកដល់ការបង្កើតប្រាក់ចំណូលពីអាជីវកម្ម ប្រតិបត្តិការអចលនទ្រព្យក៏ត្រូវបានគេយកពន្ធផងដែរ។ នៅដើមដំបូងរ៉ូមមានពន្ធលើមរតក ៥% ក្រោយមក ១០% ទោះជាយ៉ាងណាសាច់ញាតិជិតស្និតរបស់អ្នកស្លាប់ គឺត្រូវបានលើកលែងការបង់ពន្ធ។

ពន្ធបានក្លាយជាប្រធានបទសំខាន់នៃភាពចម្រោងចម្រាស ផ្នែកនយោបាយនៅទូទាំងប្រវត្តិសាស្ត្រ សូម្បីតែមុនពេលដែលពួកគេចាប់បង្កើតនូវចំណែកនៃប្រាក់ចំណូលជាតិក៏ដោយ។ ឧទាហរណ៍ៈដ៏ល្បីល្បាញមួយគឺការបះបោរនៃអាណានិគមអាមេរិចប្រឆាំងនិងចក្រភពអង្គគ្លេសនៅពេលដែលអាណានិគមនិយមបានបដិសេធមិនព្រមបង់ពន្ធ ដែលដាក់ឱ្យសភាដែលពួកគេគ្មានសម្លេង ដូច្នេះពាក្យស្លោកថា "**គ្មានការយកពន្ធដោយគ្មានតំណាង**"។ ឧទាហរណ៍ៈមួយទៀត គឺបដិវត្តន៍បារាំងឆ្នាំ ១៧៨៩ ដែលការបែងចែកមិនស្មើភាពនៃបន្ទុកពន្ធ គឺជាកត្តាចម្បង[5]។

## ២.២ គោលបំណងនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស

**២.២.១ និយមន័យវិសោធនកម្ម**

**វិសោធនកម្ម** សំដៅដល់ការកែប្រែ ឬបន្ថែមទៅលើបទដ្ឋាន និងមាត្រានៃច្បាប់រដ្ឋធម្មនុញ្ញដូចជា ច្បាប់អន្តរជាតិ ឬរដ្ឋធម្មនុញ្ញ និងច្បាប់ក្នុងស្រុកមួយឬច្រើន[6]។

**វិសោធនកម្ម** គឺជាលំហាត់នៃកាកែប្រែ ឬធ្វើឱ្យមានការរីកចម្រើនលើអ្វីមួយ ដើម្បីបំពេញតាមតម្រូវការថ្មី ឬធ្វើឱ្យវាប្រសើរឡើង។

**វិសោធនកម្ម** គឺការកែសម្រួលឱ្យប្រសើរឡើង។

**វិសោធនកម្ម** គឺជាអំពើមួយ ដែលគេធ្វើការរម្លឹងសេចក្តីទៅលើអត្ថបទគតិយុត្តណាមួយ។

**វិសោធនកម្ម** សំដៅលើការកែប្រែ ឬការលុបចោលនូវខ្លឹមសារនៃអត្ថបទ ដោយមានមូលហេតុសមហេតុផល ហើយត្រូវមានជំនួសដោយខ្លឹមសារថ្មី[7]។

---

[4] សាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា. រៀបរៀងដោយ វ៉ែន ឈុនហួត. *ពន្ធដារ*. ទំព័រទី១. ៩១ទំព័រ. Retrieved from https://chandaracitc.weebly.com/uploads/1/3/0/1/13016555/taxation.pdf (Accessed 13.03.25)

[5] លី ប៊ុណ្ណា. (២០២៤). *របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់* ទំព័រទី៥

[6] KHsearch. Lawyers. (2024, April 22). *តើវិសោធនកម្មសំដៅដល់អ្វី?* Retrieved from https://www.khsearch.com/qna/30966 (Accessed 13.03.25)

[7] YouTube. Law Lyheng. (2020, December 23). *វិសោធនកម្ម*. Retrieved from https://www.youtube.com/watch?v=mo59-897_GE (Accessed 13.03.25)

### ២.២.២ ប្រវត្តិនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស

ការធ្វើវិសោធនកម្មលើពន្ធប្រាក់បៀវត្សនៅកម្ពុជា បានឆ្លងកាត់ការផ្លាស់ប្តូរជាច្រើនក្នុងអំឡុងពេលកន្លងមក ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ការផ្លាស់ប្តូរទាំងនេះមានគោលបំណងធានាថា ប្រព័ន្ធពន្ធប្រាក់បៀវត្សមានភាពត្រឹមត្រូវ និងសមស្របសម្រាប់ប្រជាជនកម្ពុជា។

ក្នុងអំឡុងពេលចុងក្រោយនេះ ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សបានផ្តោតលើការកែប្រែអត្រាពន្ធ និងកម្រិតប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ។ ការផ្លាស់ប្តូរទាំងនេះមានគោលបំណងបន្ធូរបន្ថយបន្ទុកពន្ធលើបុគ្គលដែលមានប្រាក់បៀវត្សទាប និងធានាថាការបង់ពន្ធមានភាពត្រឹមត្រូវសម្រាប់បុគ្គលដែលមានប្រាក់បៀវត្សខ្ពស់។

សេចក្តីណែនាំលេខ០០២ សហវ.អពដ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ដែលអនុលោមតាមមាត្រា៤៧ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧[8]។

សេចក្តីណែនាំលេខ០០៦ សហវ.អពដ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ អនុលោមតាមមាត្រា៥ នៃអនុក្រឹតលេខ០៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ យោងអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២[9]។

### ២.២.៣ ប្រភេទពន្ធអាករ

ពន្ធអាករនៅក្នុងប្រទេសកម្ពុជាមានចំនួន១៦ ដូចជាៈ

១. ពន្ធលើប្រាក់ចំណូលលើប្រាក់ចំណូល
២. ពន្ធលើប្រាក់បៀវត្ស
៣. អាករលើតម្លៃបន្ថែម
៤. ពន្ធអប្បបរមា
៥. ពន្ធកាត់ទុកទូទៅ
៦. អាករពិសេស
៧. ពន្ធប្រាក់ចំណេញមូលធន
៨. អាករសម្រាប់បំភ្លឺសាធារណៈ
៩. អាករលើការស្នាក់នៅ
១០. ពន្ធលើមធ្យោបាយដឹកជញ្ជូន

---

[8] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២០១៨). សារាចរណែនាំលេខ០០២ សហវ.អពដ. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨. *ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី*

[9] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២០២០). សារាចរណែនាំលេខ០០៦ សហវ.អពដ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០. *ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី*

១១. ពន្ធប៉ាតង់
១២. ពន្ធលើដីធ្លីមិនប្រើប្រាស់
១៣. ពន្ធប្រថាប់ត្រា
១៤. ពន្ធលើផ្ទាំងផ្សព្វផ្សាយ
១៥. ពន្ធលើអចលនទ្រព្យ
១៦. ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ[10]។

## ២.៣ ប្រាក់ពន្ធដែលប្រមូលបានពីពន្ធលើប្រាក់បៀវត្សបានផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ

### ២.៣.១ និយមន័យពន្ធលើប្រាក់បៀវត្ស

**ពន្ធលើប្រាក់បៀវត្ស** សំដៅដល់ប្រភេទពន្ធដែលប្រមូលលើប្រាក់បៀវត្សរបស់និយោជិតតាមរយៈការកាត់ទុកដោយនិយោជក។ នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជាវាក្យសព្ទ "ពន្ធលើប្រាក់បៀវត្ស" សំដៅដល់ពន្ធប្រចាំខែលើប្រាក់បៀវត្ស ដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ។ ក្នុងន័យនេះវាក្យសព្ទ "**ប្រាក់បៀវត្ស**" សំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានានិងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឱ្យដល់និយោជិក ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិកចំពោះការបំពេញសកម្មភាពបម្រើការងារ[11]។

**ពន្ធលើប្រាក់បៀវត្ស** ជាប្រភេទពន្ធប្រយោលដែលរដ្ឋដកហូតពីនិយោជិតនិវាសនជនដែលមានប្រាក់បៀវត្សប្រភពកម្ពុជា ប្រភពក្រៅកម្ពុជា និងនិយោជិតអនិវាសនជនដែលមានបៀវត្សប្រភពកម្ពុជា តាមរយៈនិយោជកនិវាសនជន[12]។

### ២.៣.២ ប្រវត្តិពន្ធលើប្រាក់បៀវត្ស

**ពន្ធលើប្រាក់បៀវត្ស** គឺជាពន្ធដែលដាក់លើនិយោជក ឬនិយោជិត ហើយជាធម្មតាត្រូវបានគណនាជាភាគរយនៃប្រាក់ខែដែលនិយោជកបង់ឱ្យបុគ្គលិករបស់ពួកគេ។ តាមច្បាប់ពន្ធលើប្រាក់បៀវត្សខ្លះ គឺជាបន្ទុករបស់និយោជិត ហើយខ្លះទៀតធ្លាក់លើនិយោជក ប៉ុន្តែអ្នកសេដ្ឋកិច្ចស្ទើរតែទាំងអស់បានយល់ស្របថា អត្រាសេដ្ឋកិច្ចពិតប្រាកដនៃពន្ធលើប្រាក់បៀវត្សមិនប៉ះពាល់ដល់ភាពខុសគ្នានេះទេ ហើយភាគច្រើន ឬទាំងស្រុងលើកម្មករក្នុងទម្រង់ជាប្រាក់ឈ្នួលទាប។ ដោយសារតែពន្ធលើប្រាក់បៀវត្សធ្លាក់លើប្រាក់ឈ្នួលទាំងស្រុងមិនមែនលើការត្រឡប់មកវិញនៃការវិនិយោគផ្នែកហិរញ្ញវត្ថុ ឬរូបវន្តទេ ពន្ធលើប្រាក់បៀវត្សអាចរួមចំណែកដល់ការវិនិយោគតិចនៅក្នុងមូលធនមនុស្ស ដូចជាការអប់រំឧត្តមសិក្សាជាដើម។

ពន្ធលើប្រាក់បៀវត្សត្រូវបានកកើតឡើងដំបូងនៅក្នុងឆ្នាំ១៨៦១ ដោយសាធារណរដ្ឋអាមេរិក ហើយបន្តសាយភាយទៅបណ្តាប្រទេសជុំវិញសកលលោកបានយកច្បាប់ពន្ធនេះទៅអនុវត្តជាបន្តបន្ទាប់ដូចជា នៅបណ្តាប្រទេសនៅទ្វីបអឺរ៉ុប ទ្វីបអាស៊ី...។ ហើយបណ្តាប្រទេសនីមួយៗក៏បានរៀបចំកែសម្រួលឱ្យស្របទៅ

[10] វិទ្យាស្ថាន វ៉ាន់ដា. (២០២៤). *ច្បាប់ពន្ធដារកម្ពុជា.* បោះពុម្ពលើកទី១. ទំព័រទី៤. ភ្នំពេញ។
[11] អគ្គនាយកដ្ឋានពន្ធដា. (២០២២). *សទ្ទានុក្រមពន្ធដារ.* បោះពុម្ពលើកទី១. ទំព័រទី១៣៧. ភ្នំពេញ។
[12] វិទ្យាស្ថានវ៉ាន់ដា. (២០២២). *សៀវភៅគណនេយ្យអនុវត្តន៍ និងពន្ធ ក្រុមហ៊ុនសេវាកម្ម.* បោះពុម្ពលើកទី៣. ទំព័រទី២. ភ្នំពេញ។

តាមប្រទេសរៀងៗខ្លួន ដោយប្រទេសខ្លះបានកំណត់ការបង់ពន្ធលើប្រាក់បៀវត្សតាមប្រាក់ចំណូលប្រចាំឆ្នាំគិតជាភាគរយ ហើយក៏មានប្រទេសខ្លះទៀតបានកំណត់ជាប្រចាំខែសម្រាប់ការបង់ និងមានប្រទេសខ្លះទៀតបានកំណត់ទៅតាមតំបន់ដូចជា តំបន់ទីប្រជុំជន និងតំបន់ដាច់ស្រយាល។ ក្នុងនោះប្រទេសកម្ពុជាក៏បានយកច្បាប់ពន្ធលើប្រាក់បៀវត្សមកអនុវត្តផងដែរនៅក្នុងឆ្នាំ ១៩៩៤ ដោយបានកំណត់ការបង់ពន្ធលើប្រាក់បៀវត្សជាប្រចាំខែទៅតាមអត្រាកំណើនតាមថ្នាក់។ ឧទាហរណ៍ៈមានប្រទេសដូចជាៈ

ពន្ធលើប្រាក់បៀវត្សនៅប្រទេសអូស្ត្រាលីត្រូវបានកំណត់ និងកាត់ដោយរដ្ឋាភិបាលលើនិយោជកផ្អែកលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សដែលពួកគេបានបង់។ អត្រាពន្ធលើប្រាក់បៀវត្សប្រែប្រួលរវាងរដ្ឋ។ ជាធម្មតាពន្ធលើប្រាក់បៀវត្សអនុវត្តចំពោះប្រាក់ឈ្នួលលើសពីកម្រិតដែលវាប្រែប្រួលផងដែរ។ ក្រុមនៃក្រុមហ៊ុនអាចត្រូវបានយកពន្ធជាអង្គភាពតែមួយដែលប្រតិបត្តិការរបស់ពួកគេត្រូវបានរួមបញ្ចូលយ៉ាងសំខាន់ ឬពាក់ព័ន្ធ។ នេះមានសារៈសំខាន់ក្នុងការដាក់ជាក្រុមនៃចំនួនប្រាក់បៀវត្សក្នុងការកំណត់ថា តើកម្រិតពន្ធបានឈានដល់កម្រិតណា? អត្រាពន្ធលើប្រាក់បៀវត្សប្រចាំឆ្នាំត្រូវបានកំណត់តាមតំបន់ ហើយអត្រាដែលកំណត់ចន្លោះពី ៨% - ៦.១០% ក្នុងមួយឆ្នាំ។

ប្រទេសអូទ្រីសប្រជាជនរស់នៅប្រទេសអូទ្រីសទាំងអស់ត្រូវជាប់ពន្ធលើប្រាក់ចំណូលដែលពួកគេត្រូវទទួលបាន។ មនុស្សម្នាក់ត្រូវបានចាត់ទុកជាអ្នករស់នៅ បន្ទាប់ពីការស្នាក់នៅរយៈពេល៦ខែ នៅក្នុងប្រទេសអូទ្រីស។ អត្រាពន្ធសម្រាប់ប្រាក់ចំណូលផ្ទាល់ខ្លួនគឺចន្លោះពី ០%-៥៥% ទៅតាមកម្រិតប្រាក់ចំណូលដែលពួកគេទទួលបានក្នុងមួយឆ្នាំ។

នៅប្រទេសប្រេស៊ីល និយោជកត្រូវបានតម្រូវឱ្យបង់ពន្ធកាត់ទុក ១១% នៃប្រាក់ឈ្នួលរបស់និយោជិតសម្រាប់សន្តិសុខសង្គម និងភាគរយជាក់លាក់ជាពន្ធលើប្រាក់ចំណូល (យោងទៅតាមច្បាប់ពន្ធដែលអាចអនុវត្តបាន)។ និយោជកត្រូវតម្រូវឱ្យរួមចំណែកបន្ថែម ២០% នៃតម្លៃប្រាក់បៀវត្សសរុបដល់ប្រព័ន្ធសន្តិសុខសង្គម។ អាស្រ័យលើសកម្មភាពចម្បងរបស់ក្រុមហ៊ុន និយោជកក៏ត្រូវតែរួមចំណែកដល់កម្មវិធីធានារ៉ាប់រង និងការអប់រំដែលផ្តល់មូលនិធិដោយសហព័ន្ធផងដែរ។ លើសពីនេះមានការដាក់ប្រាក់ដែលត្រូវការចំនួន ៨% នៃប្រាក់ឈ្នួលរបស់និយោជិត (មិនត្រូវបានកាត់ទុកពន្ធពីគាត់) ទៅក្នុងគណនីធនាគារដែលអាចដកបាននៅពេលដែលនិយោជិតត្រូវបានបណ្តេញចេញ ឬស្ថិតក្រោមកាលៈទេសៈពិសេសមួយចំនួនផ្សេងទៀតដូចជាជំងឺធ្ងន់ធ្ងរ (ហៅថា "សន្តិសុខមូលនិធិសម្រាប់រយៈពេលនៃការងារ")។ ការរួមចំណែកទាំងអស់នេះស្មើនឹងបន្ទុកពន្ធសរុបស្មើរតែ ៤០% នៃប្រាក់បៀវត្សសម្រាប់និយោជក និង ១៥% នៃប្រាក់ឈ្នួលរបស់និយោជិត។ ប្រទេសកាណាដាអនុវត្តពន្ធលើប្រាក់បៀវត្សរ៍ ២% ដល់បុគ្គលិកទាំងអស់[13]។

**២.៣.៣ ការគណនាពន្ធលើប្រាក់បៀវត្ស**

ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សដោយយកចំនួនប្រាក់បៀវត្សជាប់ពន្ធសរុប ដកចេញនូវទាយជ្ជទានសម្រាប់សហព័ទ្ធ និងកូនក្នុងបន្ទុក។ ដោយឡែកចំពោះកម្មករនិយោជិត រោងចក្រ សហគ្រាស ប្រាក់បៀវត្សជាប់ពន្ធ ត្រូវបានអនុញ្ញាតឱ្យដក ចេញ

[13] Symmetry. (2017, September). *The History of Payroll Tax*. Retrieved from https://www.symmetry.com/payroll-tax-insights/the-history-of-payroll-tax (Accessed 15.03.25)

បន្ថែមទៀតនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ដូចមានចែងក្នុងសារាចរលេខ-០១១ សហវ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម។

បន្ទាប់មកត្រូវពិនិត្យមើលថា តើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងអត្រាពន្ធណាមួយ ទើបយកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើសប្រាក់ពន្ធសម្រាប់ថ្នាក់អត្រាពន្ធនោះ។ លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១,៥០០,០០០រៀលដំបូង និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

**កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធត្រូវបានកំណត់ដូចខាងក្រោម៖**

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|
| ពី ០៛ ដល់ ១,៥០០,០០០៛ | 0% | ០ ៛ |
| ពី ១,៥០០,០០១៛ ដល់ ២,០០០,០០០៛ | ៥% | ៧៥,០០០ ៛ |
| ពី ២,០០០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% | ១៧៥,០០០ ៛ |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% | ៦០០,០០០ ៛ |
| លើសពី ១២,៥០០,០០០៛ | ២០% | ១,២២៥,០០០ ៛ |

**<u>រូបមន្ត៖</u>**

- ទាយជ្ជទានសហព័ទ្ធ និងកូនក្នុងបន្ទុក = ១៥០,០០០៛ × សហព័ទ្ធ និងចំនួនកូនក្នុងបន្ទុក
- មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស(មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) - ទាយជ្ជទានសហព័ទ្ធ និងកូនក្នុងបន្ទុក
- ពន្ធលើប្រាក់បៀវត្ស (ពបវ) = មូលដ្ឋានគិត ពបវ×អត្រាពន្ធ - លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ (លបព)

**<u>កំណត់សម្គាល់៖</u>**

ចំពោះកម្មករនិយោជិតនៃរោងចក្រ សហគ្រាស ប្រសិនបើប្រាក់បៀវត្សជាប់ពន្ធ (បវ) មានរួមបញ្ចូលនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ប្រាក់ឧបត្ថម្ភនោះត្រូវបានអនុញ្ញាតឱ្យដកពីប្រាក់បៀវត្សជាប់ពន្ធ (បវ)[14] ។



**២.៣.៤ និយមន័យសេដ្ឋកិច្ច**

និយមន័យទូទៅសេដ្ឋកិច្ច គឺសិក្សាអំពីមនុស្សជាតិនៅក្នុងការងារជំនួញធម្មតានៃជីវិតរស់នៅ។ តាមទ្រឹស្តីសេដ្ឋកិច្ចវិទូបានឱ្យនិយមន័យសេដ្ឋកិច្ចខុសៗគ្នាជាច្រើន ប៉ុន្តែន័យសុក្រឹតមួយគឺ សេដ្ឋកិច្ចសិក្សាអំពីការប្រើប្រាស់បណ្តាធនធានដ៏កម្រដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្សដែលគ្មានព្រំដែន។ មានទ្រឹស្តីមួយទៀតបាននិយាយថា សេដ្ឋកិច្ចជាការសិក្សាអំពីយុទ្ធសាស្ត្ររបៀបប្រើប្រាស់ធនធានដើម្បីបំពេញបំណងគ្មានព្រំដែនរបស់មនុស្សដែលមានប្រព័ន្ធទាក់ទិននឹងប្រព័ន្ធផលិតកម្ម (ផ្នែកសេដ្ឋកិច្ចនិងឧស្សាហកម្ម) ប្រព័ន្ធបែងចែក (ផ្នែកពាណិជ្ជកម្ម) និងប្រព័ន្ធប្រើប្រាស់ទំនិញសេដ្ឋកិច្ច (ផ្នែកអតិថិជន ផ្នែកគមនាគមន៍ និងដឹកជញ្ជូន) ។

**សេដ្ឋកិច្ច (Economy)** គឺជាប្រព័ន្ធសកម្មភាពផលិត (production) ចែកចាយ (distribution) និងប្រើប្រាស់ធនធាន (consumption of resources) ដែលបុគ្គល ក្រុមហ៊ុន និងរដ្ឋធ្វើដើម្បីបំពេញតម្រូវការរស់នៅប្រចាំថ្ងៃ។

**សេដ្ឋកិច្ច (Economy)** ជាវិធីដែលសង្គមគ្រប់គ្រងធនធានដើម្បីបង្កើតទំនិញ និងសេវាកម្ម បន្ទាប់មកចែកចាយវាឱ្យប្រជាជនប្រើប្រាស់។

**សេដ្ឋកិច្ច (Economy)** គឺជាសកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងការផលិត ការចំណាយ ការចែកចាយ និងការប្រើប្រាស់ធនធានដើម្បីបំពេញតម្រូវការរបស់មនុស្ស។ នៅក្នុងបរិបទពន្ធដារ "សេដ្ឋកិច្ច" គឺសំដៅលើប្រព័ន្ធនៃការប្រើប្រាស់ពន្ធ ដើម្បីសម្របសម្រួលសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេស។

**សេដ្ឋកិច្ច (Economy)** គឺជាសំណុំនៃទំនាក់ទំនង ផលិតកម្ម ការប្រើប្រាស់ ការទិញដូរ ការបែងចែងធនធានកម្រទាំងឡាយនៅក្នុងសង្គម ឬក៏ ទាក់ទងទៅនឹង។ សេដ្ឋកិច្ច មានពីរប្រភេទធំៗគឺ មីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ច។ ប្រព័ន្ធសេដ្ឋកិច្ចចែកចេញជាបីគឺ សេដ្ឋកិច្ចផែនការ សេដ្ឋកិច្ចទីផ្សារ និងសេដ្ឋកិច្ចចម្រុះ[15]។

**២.៣.៥ ប្រវត្តិសេដ្ឋកិច្ច**

ប្រវត្តិសេដ្ឋកិច្ចសកល គឺជាការសិក្សាពីការវិវត្តន៍សេដ្ឋកិច្ចរបស់មនុស្សជាតិគ្រប់បរិបទនៅលើពិភពលោកតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។ វាបង្ហាញពីរបៀបដែលសង្គមមនុស្សបានផលិត ចែកចាយ និងប្រើប្រាស់ធនធានតាមរយៈសម័យនានា។

**១. សម័យបុរាណ** នៅសម័យបុរាណ ប្រជាជនរស់នៅក្នុងសង្គមកសិកម្ម ឬឧស្សាហកម្មតូចៗ ដែលប្រើប្រាស់ការដូរញដូរ (barter) ជាវិធីសេដ្ឋកិច្ចសំខាន់។ ប្រទេសជាច្រើននៅអាស៊ី អាហ្វ្រិក និងអឺរ៉ុប បានអភិវឌ្ឍវប្បធម៌ និងពាណិជ្ជកម្មតាមរយៈផ្លូវពាណិជ្ជកម្មដូចជា "ផ្លូវប៉ាកសាច់" និង "ផ្លូវសមុទ្រ"។

**២. សម័យបដិវត្តឧស្សាហកម្ម** ចាប់ពីសតវត្សទី១៨ ប្រទេសអង់គ្លេស និងបន្ទាប់មកប្រទេសអឺរ៉ុបបានឈានចូលសម័យបដិវត្តឧស្សាហកម្ម។ វាបានបង្កើតការផ្លាស់ប្តូរយ៉ាងខ្លាំងលើសេដ្ឋកិច្ច ដោយមានការប្រើម៉ាស៊ីន ការផលិតសំណាង់ ដឹកជញ្ជូន និងផលិតកម្មត្រួតត្រា។ វានាំឱ្យមានការរីកចម្រើននៃទីក្រុង និងការកើនឡើងនៃជនក្រីក្រនៅតំបន់ឧស្សាហកម្ម។

[15] KHsearch. សេដ្ឋកិច្ច. (2019, January 09). *តើជាសេដ្ឋកិច្ចអ្វី?* Retrieved from https://www.khsearch.com/qna/13654 (Accessed 15.03.25)

**៣. សម័យសង្គ្រាមលោក** នៅសតវត្សទី២០ ពិភពលោកបានប្រឈមមុខនឹងសង្គ្រាមលោកទី១ និងទី២ ដែលបានបំផ្លាញសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ បន្ទាប់ពីសង្គ្រាមទី២ ប្រទេសខាងលិចបានកសាងប្រព័ន្ធសេដ្ឋកិច្ចថ្មី ដូចជា *Bretton Woods System* កំណើតរបស់ IMF, World Bank និងអង្គការពាណិជ្ជកម្ម។

**៤. សម័យសេដ្ឋកិច្ចសាកល (Globalization)** ចាប់ពីទសវត្ស ១៩៨០ មកប្រទេសនៅទូទាំងពិភពលោក បានចូលរួមក្នុងសេដ្ឋកិច្ចសាកលដោយការបើកទីផ្សារ បង្កើនពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគអន្តរជាតិ។ ប្រទេសចិនបានក្លាយជាអំណាចសេដ្ឋកិច្ចថ្មី និងមានឥទ្ធិពលខ្លាំង។ បច្ចេកវិទ្យា និងបណ្តាញអ៊ីនធឺណេតបាន ផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចទាំងមូល។

**៥. សម័យបច្ចុប្បន្ន** សេដ្ឋកិច្ចពិភពលោកសព្វថ្ងៃកំពុងប្រឈមមុខនឹងបញ្ហាច្រើន ដូចជា៖

- វិបត្តិហិរញ្ញវត្ថុ (Financial crisis)
- បំផ្លាញបរិស្ថាន
- ភាពមិនស្មើគ្នានៃចំណូល
- ផលប៉ះពាល់ពីជំងឺកូវីដ-១៩
- បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) និងប្លុកឈិន[16]។

[16] Cameron, Rondo & Neal, Larry. (2015). *A Concise Economic History of the World: From Paleolithic Times to the Present.* Oxford University Press.

# ជំពូកទី៣

# ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ



អ្នកប្រកបអាជីវកម្មមួយចំនួននៅមិនទាន់យល់ដឹងអំពីពន្ធដារនេះគ្រប់គ្រាន់នៅឡើយទេ។ ពន្ធដារជាម្ចាស់បំណុលរបស់អ្នកប្រកបអាជីវកម្ម ដែលមានផលរបរជាប់ពន្ធទាំងអស់ ដែលអ្នកទាំងនោះត្រូវបង់ ជូនរដ្ឋតាមពេលកំណត់។ តែវាជាភារកិច្ចរបស់អ្នកប្រកបអាជីវកម្ម ដែលត្រូវចូលរួមចំណែកក្នុងការទ្រទ្រង់ ដល់ការអភិវឌ្ឍប្រទេស បើយើងគិតថាវាជាបំណុលនោះក៏ត្រូវម្យ៉ាងតែប្រសិនបើគិតអំពីអ្វីដែលម្ចាស់ក្រុមហ៊ុនទទួលបានពីរដ្ឋវិញក៏មិនតិចដែល។ ទាំងនោះ គឺជាសិទ្ធប្រកបអាជីវកម្មស្របច្បាប់មួយដែលមានការទទួលស្គាល់ពីស្ថាប័នច្បាប់ និងមានការការពារពីច្បាប់ដោយមិនមានអាជីវកម្មណាមកបន្លំបាន។

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ

ប្រទេសកម្ពុជាបានឆ្លងកាត់នូវរបបជាច្រើនដំណាក់កាល ក្នុងដំណាក់កាលនីមួយៗមានការប្រើហិង្សាដើម្បីធ្វើបដិវត្តិន៍។ មានការបង្កើតថ្មីហើយក៏ត្រូវបានកំទិចផងដែរ រាល់ក្រសួងស្ថាប័ននានា ដែលបានបង្កើតក៏ត្រូវបានបិទទៅតាមសម័យកាលនីមួយៗ។ យ៉ាងណាមិញ ស្ថាប័នពន្ធដារក៏មិនខុសពីស្ថាប័នដ៏ទៃទៀតដែរ គឺត្រូវបានកំទិចដូចគ្នា។

ពន្ធដារត្រូវបានបង្កើតដំបូងជា "**នាយកដ្ឋានពន្ធដារ**" នៅឆ្នាំ ១៩៥៣ ក្រោយពីបានទទួលឯករាជ្យពីបារាំងប្រទេសបានសន្តិភាពមិនបានប៉ុន្មាន នៅឆ្នាំ ១៩៧០ ដល់ឆ្នាំ១៩៧៥ ក៏មានការធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ

ចេញពីដំណែងដោយសេនាប្រមុខលន់នល់ដែលគាំទ្រដោយសហរដ្ឋអាមេរិក។ ក្រោយមកទៀត ឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រព័ន្ធពន្ធដារត្រូវបានលុបចោលទាំងស្រុងដោយសារបបប្រល័យពូជសាសន៍ខ្មែរក្រហម ដែលបានអូសបន្លាយអស់រយៈពេលជាងបីឆ្នាំ។ ក្រោយរបបខ្មែរក្រហមត្រូវបានដួលរលំដោយជ័យជម្នះ ថ្ងៃប្រាំពីរ ខែមករា នៅឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩៣ ត្រូវបានបង្កើតឡើងវិញម្តងទៀត ដែលមានឈ្មោះថា "**នាយកដ្ឋានពន្ធដារឧស្សាហពាណិជ្ជ ក្រសួងហិរញ្ញវត្ថុ**"។ ក្រោយដំណើរការបានមួយរយៈ ពន្ធដារត្រូវបានដំឡើងទៅជា "**អគ្គនាយកដ្ឋានពន្ធដារ**" ចាប់ពីឆ្នាំ២០០៨មកដល់បច្ចុប្បន្ននេះ ក្រោមការដឹកនាំរបស់ **ឯកឧត្តមគង់ វិបុល** ដែលជាប្រតិភូរបស់រាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។ បច្ចុប្បន្នពន្ធដារបានធ្វើការកែទម្រង់ស៊ីជម្រៅទៅលើប្រព័ន្ធពន្ធដារមួយចំនួន ដែលជាហេតុនាំឱ្យពន្ធដារមានការីកចម្រើនយ៉ាងខ្លាំងប្រកបដោយគុណភាព និងការជឿទុកចិត្តបានពីសំណាក់អ្នកជាប់ពន្ធគ្រប់ជាន់ថ្នាក់។ ការប្រមូលចំណូលពន្ធ មានការកើនឡើងរាល់ឆ្នាំដែលជាហេតុនាំ ឱ្យចំណូលជាតិមានកើនឡើង មន្ត្រីរាជការ ការកសាងមន្ទីរពេទ្យ សាលារៀន ស្ពានថ្នល់ អគារសាធារណៈ ប៉ូលិស ទាហ៊ាន ប្រព័ន្ធជារាសាស្ត្រ ត្រូវបានអភិវឌ្ឍន៍និងកសាងជាបន្តបន្ទាប់ ប្រាក់ខែមន្ត្រីរាជការត្រូវបានដំឡើងជាបន្តបន្ទាប់។ ទាំងនេះដោយសារតែចំណូលរបស់ជាតិមាន ការកើនឡើងអាចធានាបាន និងគាំទ្រដល់ការអភិវឌ្ឍន៍ទាំងនេះឱ្យនៅតែបន្តការកសាងនិងពង្រីកសក្តានុពលឱ្យកាន់តែខ្លាំងក្លា។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់អគ្គនាយកដ្ឋានពន្ធដារ

#### ក.ចក្ខុវិស័យ

ចក្ខុវិស័យនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ គឺផ្សារភ្ជាប់នឹងចក្ខុវិស័យនៃការអភិវឌ្ឍកម្ពុជា ដោយផ្តោតលើការប្រប្រមូលចំណូលក្នុងស្រុកឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីឆ្លើយតប ឱ្យបានសមស្របទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយចិរភាព។ កម្ពុជាមានចក្ខុវិស័យសម្រេច ឱ្យបាននូវឋានៈ ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ដោយចំណូលសម្រាប់ប្រជាជនម្នាក់ៗក្នុងមួយឆ្នាំនឹងកើតឡើងដល់រង្វង់ ៤០០០ ទៅ ៥០០០ ដុល្លារអាមេរិកនៅឆ្នាំ២០៣០ តាមរយៈការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ដែលមានមូលដ្ឋានរឹងមាំនិងភាពធន់ខ្ពស់ សមធម៌នៃការបែងចែកផ្លែផ្កានៃកំណើន ការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាបានប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ដែលមានបរិយាប័ន្ន ផ្តល់ឱកាសស្មើគ្នា និងប្រកបដោយយុត្តិធម៌។ ក្នុងន័យនេះ ចំណូលក្នុងស្រុករបស់កម្ពុជានឹងក្លាយជាម្ចាស់យ៉ាងសំខាន់ក្នុង ការទ្រទ្រង់កំណើនសេដ្ឋកិច្ច ការផ្តល់ការងារជូនប្រជាពលរដ្ឋ តាមរយៈការបែងចែកឡើងវិញនូវផលទុនជាតិក្នុង ក្របខ័ណ្ឌនៃប្រព័ន្ធថវិកាជាតិដ៏សមស្របមួយ។ ម៉្យាងទៀត ការកៀរគរចំណូលឱ្យអស់សក្តានុពល គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ពង្រឹងភាពជាម្ចាស់លើការអភិវឌ្ឍន៍ប្រទេស និងកែពេញឱ្យបានគ្រប់គ្រាន់នៅនឹងតម្រូវការ តែចំណាយសាខារណៈចាំបាច់នានា ដើម្បីចូលរួមវិភាគទានដល់ការសម្រេចឱ្យបាននូវចក្ខុវិស័យខាងលើ។

#### ខ.បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដាតាមការៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌតាមការកំណត់ នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទញ្ញត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាព សាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

**គ.គោលដៅ**

យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមមានគោលបំណងពង្រឹងរដ្ឋបាលសារពើពន្ធ ដែលមិនមែនសារពើពន្ធលើកកម្ពស់វប្បធម៌បង់ពន្ធ និងការគោរពច្បាប់ ដើម្បីពង្រឹងការប្រមូលចំណូលឱ្យមានប្រសិទ្ធភាពឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចទីផ្សារដែលកំពុងលូតលាស់ និងការកើនឡើងនៃចំនួនអ្នកបង់ពន្ធ ដូចជាភាពស្មុគស្មាញនៃសកម្មភាពធុរៈកិច្ចក្នុងសម័យទំនើប ព្រមទាំងផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវការផ្តល់សេវាជូនអ្នកបង់ពន្ធ រួមចំណែកកែលម្អបរិយាកាសវិនិយោគ និងការអភិវឌ្ឍលើវិស័យឯកជនជានាសមធម៌ និងយុត្តិធម៌សម្រាប់ពលរដ្ឋទាំងអស់។

ដើម្បីសម្រេចគោលបំណងខាងលើយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមបានកំណត់គោលដៅដូចតទៅៈ

១-ប្រមូលចំណូលចរន្តសរុបឱ្យកើនបានយ៉ាងតិចបំផុត ០៥ ពិន្ទុភាគរយ បន្ថែមលើផលធៀបរវាងចំណូលចរន្ត និងផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ ដោយត្រូវកើនពី ១៥.១៨% នៅឆ្នាំ ២០១៤ ដល់ ១៧.៣៥% នៅឆ្នាំ ២០១៨។

២-ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍដើម្បីរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចគោលដៅអភិវឌ្ឍជាតិ ដែលស្របនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីត្រៀមខ្លួនក្លាយជាប្រទេសចំណូលមធ្យម កម្រិតខ្ពស់នាពេលខាងមុខ។

៣-ពង្រីកលំហថវិកា ដើម្បីពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់គ្រប់គ្រងបំណុលប្រកបដោយចីរភាព និងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស។

៤-បង្កើនធនធានថវិកាសម្រាប់តម្រូវការបន្ទាន់ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

#### ក.រចនាសម្ព័ន្ធគ្រប់គ្រង



ក្នុងនោះនាយកដ្ឋានថ្នាក់កណ្តាលក្រោមចំណុះរបស់អគ្គនាយកដ្ឋានមានចំនួន៧ រួមមាន៖

⇒ នាយកដ្ឋានបុគ្គលិក និងរដ្ឋបាលហិរញ្ញវត្ថុ

⇒ នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ

⇒ នាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ

⇒ នាយកដ្ឋានត្រួតពិនិត្យ

⇒ នាយកដ្ឋានព័ត៌មានវិទ្យា

⇒ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

⇒ នាយកដ្ឋានសវនកម្មសហគ្រាស។

**ខ. តួនាទី និងភារកិច្ចគណៈគ្រប់គ្រង**

**អគ្គនាយកដ្ឋានពន្ធដារមានតួនាទី និងភារកិច្ចដូចជា៖**

- ចូលរួមរៀបចំគោលនយោបាយសារពើពន្ធស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបរិបទអន្តរជាតិ
- រៀបចំសេចក្តីព្រាងច្បាប់លិខិតបទដ្ឋានស្តីពីពន្ធដារកំណត់បញ្ជីឯកសារ និងលិខិតគតិយុត្តិនានាសម្រាប់ការគ្រប់គ្រងប្រមូលពន្ធ
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- ចុះបញ្ជីអ្នកជាប់ពន្ធ
- ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ ផ្តល់សេវា និងព័ត៌មានដល់អ្នកជាប់ពន្ធ ដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ
- កសាងកម្មវិធីសវនកម្ម និងបច្ចុប្បន្នភាពលើអ្នកជាប់ពន្ធ
- កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវចំពោះអ្នកជាប់ពន្ធស្របតាមច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ
- ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទបញ្ញត្តិស្តីពីពន្ធដារ
- អនុវត្តវិធានការតឹងតែង និងដាក់ទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តបទល្មើសផ្ទុយនឹងច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ
- ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ
- រៀបចំ និងអនុវត្តកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិនានាទាក់ទិននឹងពន្ធដារ
- រៀបចំផែនការជ្រើសរើស បណ្តុះបណ្តាល និងកសាងសមត្ថភាពធនធានមនុស្សទាក់ទិនទៅនឹងពន្ធដារ។

**អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចតទៅ៖**

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្តុំព័ត៌មាន

- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគោលនយោបាយសារពើពន្ធស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបរិបទអន្តរជាតិ
- រៀបចំសេចក្តីព្រាងច្បាប់លិខិតបទដ្ឋានស្តីពីពន្ធដារកំណត់បញ្ជីឯកសារ និងលិខិតគតិយុត្តិនានា សម្រាប់ការគ្រប់គ្រងប្រមូលពន្ធ
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- ចុះបញ្ជីអ្នកជាប់ពន្ធ
- ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ ផ្តល់សេវា និងព័ត៌មានដល់អ្នកជាប់ពន្ធ ដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ
- កសាងកម្មវិធីសវនកម្ម និងបច្ចុប្បន្នភាពលើអ្នកជាប់ពន្ធ
- កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ចំពោះអ្នកជាប់ពន្ធស្របតាមច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ
- ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទបញ្ញត្តិស្តីពីពន្ធដារ
- អនុវត្តវិធានការតឹងតែង និងដាក់ទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តបទល្មើស ផ្ទុយនឹងច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ
- ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ
- រៀបចំ និងអនុវត្តកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិនានាទាក់ទិននឹងពន្ធដារ
- រៀបចំផែនការជ្រើសរើស បណ្តុះបណ្តាល និងកសាងសមត្ថភាពធនធានមនុស្សទាក់ទិនទៅនឹងពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ៣.២. ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ គោលបំណងការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ

ច្បាប់ ឬបទបញ្ញត្តិដែលអគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីប្រកាសដាក់ឱ្យប្រើប្រាស់កន្លងមកតែងត្រូវបានធ្វើបច្ចុប្បន្នភាពសារជាថ្មីដើម្បី៖

- ទី១: កំណែទម្រង់ពន្ធត្រូវបានបង្កើតឡើងសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយនូវអសមភាពក្នុងការបែងចែកធនធាន។
- ទី២: កំណែទម្រង់ពន្ធត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីទ្រទ្រង់ស្ថិរភាពសេដ្ឋកិច្ច និងការបង្កើនចំណូលសាធារណៈ ។

ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស មានគោលបំណងចម្បងក្នុងការធានាថា ប្រព័ន្ធពន្ធមានប្រសិទ្ធភាព មានភាពត្រឹមត្រូវ មានភាពសមរម្យ និងសមស្របនឹងស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្នពោលគឺរួមមានដូចជា៖

- **បង្កើនប្រាក់ចំណូលរដ្ឋ** ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស មានគោលបំណងជាប្រភពប្រាក់ចំណូលរបស់រដ្ឋបន្ថែម។ ដោយបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និងការបង់ពន្ធត្រឹមត្រូវពីបុគ្គលមានប្រាក់បៀវត្ស
- **ធានាថាពន្ធមានភាពសមរម្យនិងតុល្យភាព** ការផ្លាស់ប្តូរគោលនយោបាយពន្ធ គឺជាចំណាំដើម្បីធានាថាអ្នកមានប្រាក់ចំណូលខ្ពស់បង់ពន្ធសមរម្យជាងអ្នកមានចំណូលទាប។ វាជួយបែងចែកប្រាក់ចំណូលក្នុងសង្គមឱ្យបានសមភាព
- **លើកកម្ពស់ការចូលរួមបង់ពន្ធដោយស្ម័គ្រចិត្ត** ដោយធ្វើឱ្យប្រព័ន្ធពន្ធមានភាពច្បាស់លាស់ និងងាយស្រួលក្នុងការបង់ ពលរដ្ឋនឹងមានភាពស្ម័គ្រចិត្តបង់ពន្ធកាន់តែល្អ
- **កែលម្អប្រព័ន្ធបច្ចេកវិទ្យា និងរបៀបគ្រប់គ្រង** ការវិសោធនកម្មនាំឱ្យមានការចូលរួមនៃបច្ចេកវិទ្យាទំនើបដូចជា E-filing និង E-payment ដែលជួយសម្រួលដល់ទាំងអ្នកបង់ពន្ធ និងរដ្ឋបាលពន្ធ
- **ឆ្លើយតបទៅនឹងបរិបទសេដ្ឋកិច្ច និងសង្គមបច្ចុប្បន្ន** ព័ត៌មានថ្មីៗអំពីកំណើនប្រាក់បៀវត្ស ឬអត្រាស្តីពីថ្លៃជីវភាពអាចជម្រុញឱ្យត្រូវធ្វើវិសោធនកម្ម ដើម្បីធានាថាប្រជាពលរដ្ឋមិនទទួលរងការបាត់បង់ពីបរិបទសេដ្ឋកិច្ចថ្មី
- **ជម្រុញការវិនិយោគ និងការងារផ្សេងៗ** ដោយកែលម្អប្រព័ន្ធពន្ធឱ្យមានភាពច្បាស់លាស់ និងជួយបង្កើនទំនុកចិត្តរបស់អ្នកវិនិយោគ និងអភិវឌ្ឍភាពប្រកួតប្រជែងក្នុងទីផ្សារ
- **ទប់ស្កាត់ការជៀសវាងពន្ធ និងការប្រកាសចំណូលមិនត្រឹមត្រូវ** ការកែសម្រួលច្បាប់ និងនីតិវិធីពន្ធលើប្រាក់បៀវត្ស អាចជួយបង្កើនការត្រួតពិនិត្យ និងការអនុវត្តច្បាប់ពន្ធបានយ៉ាងមានប្រសិទ្ធភាព
- **ផ្គូផ្គងនឹងបរិបទសេដ្ឋកិច្ច និងការប្រកួតប្រជែង** ការធ្វើវិសោធនកម្មជួយដល់ការផ្គូផ្គងប្រព័ន្ធពន្ធនឹងនិន្នាការប្រកួតប្រជែង សេដ្ឋកិច្ចក្នុងស្រុក និងអន្តរជាតិ ដោយបង្កើតបរិយាកាសសមរម្យសម្រាប់ការវិនិយោគ និងការងារ។

### ៣.២.២ ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ

ជាការពិតណាស់ ការបង់ពន្ធពីសំណាក់បណ្តាលប្រជាពលរដ្ឋពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការកៀរគរ ចំណូលសម្រាប់ប្រទេសជាតិដើម្បីឆ្លើយតបទៅនឹងចំណាយទូទាំងប្រទេស។ ទោះជាយ៉ាងណាការដកហូតពន្ធតែងតែបង្កការឈឺចាប់ដល់អ្នកជាប់ពន្ធ ព្រោះការដកហូតពន្ធនេះ គឺត្រូវបានកាត់បន្ថយនូវបៀវត្សដែលជាប្រាក់ចំណូលផ្ទាល់របស់និយោជិតតែម្តង។ ដូច្នេះហើយបានជាការប្រមូលពន្ធលើប្រាក់បៀវត្សត្រូវធ្វើឡើងតាមរយៈគ្រប់សហគ្រាស ដែលជាអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានាដែលមានកាតព្វកិច្ចកាត់ទុក និងបង់ពន្ធលើប្រាក់បៀវត្សត្រូវប្រមូលតាមរបៀបកាត់ទុកជាមុនជារៀងរាល់ខែដោយនិយោជកនៅរាល់ពេលបើកប្រាក់បៀវត្ស។ និយោជកត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស នៅមុនពេលបើកប្រាក់បៀវត្សឱ្យដល់និយោជិត និងបង់ប្រាក់ពន្ធដែលបានកាត់ទុកនោះ ត្រូវ

ភ្ជាប់ជាមួយនូវលិខិតប្រកាសសារពើពន្ធប្រចាំខែនូវចំនួន ទឹកប្រាក់ ដែលដកហូតបានពីនិយោជិតជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលប្រាក់បៀវត្សត្រូវបានបើក។ បើនិយាយអំពីពន្ធលើប្រាក់បៀវត្សនេះវិញ គឺជាពន្ធប្រចាំខែដែលកំណត់លើប្រាក់បៀវត្សដែលបានទទួលក្នុងការបំពេញសកម្មភាពបម្រើការងារ។ សម្រាប់និយោជិតនិវាសនជន ដែលទទួលបានប្រាក់បៀវត្សពីសកម្មភាពបម្រើការងាររបស់ខ្លួនដែលទទួលបានក្នុងក្របខណ្ឌនៃការបំពេញសកម្មភាពបម្រើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្រៅកម្ពុជា គឺមានកាតព្វកិច្ចត្រូវបង់ពន្ធជូនរដ្ឋទៅតាមកម្រិតនៃប្រាក់បៀវត្សជាប់ពន្ធនីមួយៗ។

**ការធ្វើវិសោធនកម្ម និងកម្រិតនៃប្រាក់បៀវត្សជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលបានចេញនូវសេចក្តីប្រកាសកែសម្រួល និងបទបញ្ញត្តិនានាទាក់ទិននឹងពន្ធលើប្រាក់បៀវត្សចំនួន៦ ដង៖**

**លើកទី១ ឆ្នាំ១៩៩៧** (ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧) បើយោងតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ដូចមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ១១.នស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដើម្បីបានជាគុណប្រយោជន៍ដល់ថវិការដ្ឋ សម្រាប់និយោជិតនិវាសនជនប្រាក់ពន្ធត្រូវបង់ត្រូវបានកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនឹងត្រូវកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ដែលត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច។

**កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ**

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ |
|---|---|
| ពី ០៛ ដល់ ៥០០,០០០៛ | 0% |
| ពី ៥០០,០០១៛ ដល់ ១,២៥០,០០០៛ | ៥% |
| ពី ១,២៥០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% |
| លើសពី ១២,៥០០,០០០៛ | ២០% |

**លើកទី២ ឆ្នាំ២០១៥** (យោងតាមសេចក្តីណែនាំស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) អនុលោមតាមមាត្រា៤៧ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ បានធ្វើការកែសម្រួលកម្រិតប្រាក់បៀវត្សជាប់ពន្ធម្តងទៀត តាមតារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម៖

**កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ**

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ |
|---|---|
| ពី ០៛ ដល់ ៨០០,០០០៛ | 0% |
| ពី ៨០០,០០១៛ ដល់ ១,២៥០,០០០៛ | ៥% |
| ពី ១,២៥០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% |
| លើសពី ១២,៥០០,០០០៛ | ២០% |

**លើកទី៣ ឆ្នាំ២០១៧** (យោងតាមសេចក្តីណែនាំស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) អនុលោមតាមមាត្រា៤៧ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ក្រសួងសេដ្ឋកិច្ច) បានធ្វើការកែសម្រួលកម្រិតប្រាក់បៀវត្សជាប់ពន្ធម្តងទៀត តាមតារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម៖

**កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ**

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ |
|---|---|
| ពី ០៛ ដល់ ១,០០០,០០០៛ | 0% |
| ពី ១,០០០,០០១៛ ដល់ ១,៥០០,០០០៛ | ៥% |
| ពី ១,៥០០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% |
| លើសពី ១២,៥០០,០០០៛ | ២០% |

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបញ្ជាក់ទៀតថា ដើម្បីសម្រួលជីវភាពរស់នៅរបស់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិតដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ រាជរដ្ឋាភិបាលក៏បានសម្រេចធ្វើការដំឡើងកម្រិតកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះក្នុងម្នាក់ៗពី ៧៥,០០០ រៀល ដល់១៥០,០០០រៀល ក្នុងមួយខែ(កើនឡើងពីរដង)។ ការដំឡើងកម្រិតកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែតិច ដែលនាំឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សលើសពី១លានអាច និងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។

**កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ**

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|
| ពី ០៛ ដល់ ១,០០០,០០០៛ | 0% | 0 ៛ |
| ពី ១,០០០,០០១៛ ដល់ ១,៥០០,០០០៛ | ៥% | ៥០,០០០ ៛ |
| ពី ១,៥០០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% | ១២៥,០០០ ៛ |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% | ៥៥០,០០០ ៛ |
| លើសពី ១២,៥០០,០០០៛ | ២០% | ១,១៧៥,០០០ ៛ |

**លើកទី៤** ឆ្នាំ២០១៨ (យោងតាមសេចក្តីណែនាំស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) អនុលោមតាមមាត្រា៤៧ថ្មី(ពីរ)នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលកម្រិតប្រាក់បៀវត្សជាប់ពន្ធម្តងទៀត តាមតារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម៖

កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ |
|---|---|
| ពី ០៛ ដល់ ១,២០០,០០០៛ | 0% |
| ពី ១,២០០,០០១៛ ដល់ ២,០០០,០០០៛ | ៥% |
| ពី ២,០០០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% |
| លើសពី ១២,៥០០,០០០៛ | ២០% |

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ទៀតថា ដើម្បីសម្រួលដល់ស្ថានភាពនៃគ្រួសារ មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តី ឬប្រពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះក្នុងម្នាក់ៗ ១៥០,០០០ រៀល ក្នុងមួយខែ។ ការកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែទាប ធ្វើឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមាន បន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សក្នុងរង្វង់ពី ១,២០០,០០១ រៀល ដល់ ១,៦០០,០០០រៀល (ប្រមាណពី៣០០ ទៅ ៤០០ ដុល្លារអាមេរិក) អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។

កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|
| ពី ០៛ ដល់ ១,២០០,០០០៛ | 0% | 0 ៛ |
| ពី ១,២០០,០០១៛ ដល់ ២,០០០,០០០៛ | ៥% | ៦០,០០០ ៛ |
| ពី ២,០០០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% | ១៦០,០០០ ៛ |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% | ៥៨៥,០០០ ៛ |
| លើសពី ១២,៥០០,០០០៛ | ២០% | ១,២១០,០០០ ៛ |

**លើកទី៥** ឆ្នាំ២០២០ (យោងតាមសេចក្តីណែនាំស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី របស់ក្រសួងសេដ្ឋ កិច្ចនិងហិរញ្ញវត្ថុ) អនុលោមតាមមាត្រា៥ នៃអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) បានធ្វើការកែសម្រួលកម្រិតប្រាក់បៀវត្សជាប់ពន្ធម្តងទៀត តាមតារាងអត្រាកំណើនតាមថ្នាក់ថ្មីមាន ដូចខាងក្រោម៖

កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ |
|---|---|
| ពី ០៛ ដល់ ១,៣០០,០០០៛ | 0% |
| ពី ១,៣០០,០០១៛ ដល់ ២,០០០,០០០៛ | ៥% |
| ពី ២,០០០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% |
| លើសពី ១២,៥០០,០០០៛ | ២០% |

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ទៀតថា ដើម្បីសម្រួលស្ថានភាពជីវភាពគ្រួសារ មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិតដែលមាន បន្ទុកចិញ្ចឹមកូន ប្តី ឬប្រពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះក្នុងម្នាក់ៗ ១៥០,០០០ រៀលក្នុងមួយខែ។ ការកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែទាប ធ្វើឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តី ឬប្រពន្ធ ដែលមានប្រាក់បៀវត្សក្នុងរង្វង់ពី ១,៣០០,០០១ រៀល ដល់ ២,០០០,០០០ រៀល (ប្រមាណពី ៣២៥ ទៅ ៥០០ដុល្លាអាមេរិក) អាចនឹងផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។

កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|
| ពី ០៛ ដល់ ១,៣០០,០០០៛ | 0% | 0 ៛ |
| ពី ១,៣០០,០០១៛ ដល់ ២,០០០,០០០៛ | ៥% | ៦៥,០០០ ៛ |
| ពី ២,០០០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% | ១៦៥,០០០ ៛ |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% | ៥៩០,០០០ ៛ |
| លើសពី ១២,៥០០,០០០៛ | ២០% | ១,២១៥,០០០ ៛ |

**លើកទី៦** ឆ្នាំ២០២២ (យោងតាមប្រកាសរាជរដ្ឋាភិបាលកម្ពុជាលេខ១៩៦ អនក្រ.បក អនុក្រឹត្យស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ មាត្រា៤ តារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ អនុលោមតាមមាត្រា៤៧ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ) បានធ្វើការកែសម្រួលកម្រិតប្រាក់បៀវត្សជាប់ពន្ធម្តងទៀត តាមតារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម៖

**កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ**

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ |
|---|---|
| ពី 0៛ ដល់ ១,៥០០,០០០៛ | 0% |
| ពី ១,៥០០,០០១៛ ដល់ ២,០០០,០០០៛ | ៥% |
| ពី ២,០០០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% |
| លើសពី ១២,៥០០,០០០៛ | ២០% |

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ទៀតថា ដើម្បីសម្រួលស្ថានភាពជីវភាពគ្រួសារ មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិតដែលមាន បន្ទុកចិញ្ចឹមកូន ប្តី ឬប្រពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះ ក្នុងម្នាក់ៗ ១៥០,០០០ រៀលក្នុងមួយខែ។ ការកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែទាប ធ្វើឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តី ឬប្រពន្ធ និងដែលមានប្រាក់បៀវត្សក្នុងរង្វង់ពី ១,៥០០,០០១ រៀល ដល់ ២,០០០,០០០ រៀល (ប្រមាណពី ៣៧៥ ទៅ ៥០០ ដុល្លារអាមេរិក) អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។

**កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងអត្រាពន្ធ**

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | អត្រាពន្ធ | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|
| ពី 0៛ ដល់ ១,៥០០,០០០៛ | 0% | 0 ៛ |
| ពី ១,៥០០,០០១៛ ដល់ ២,០០០,០០០៛ | ៥% | ៧៥,០០០ ៛ |
| ពី ២,០០០,០០១៛ ដល់ ៨,៥០០,០០០៛ | ១០% | ១៧៥,០០០ ៛ |
| ពី ៨,៥០០,០០១៛ ដល់ ១២,៥០០,០០០៛ | ១៥% | ៦០០,០០០ ៛ |
| លើសពី ១២,៥០០,០០០៛ | ២០% | ១,២២៥,០០០ ៛ |

**រូបមន្ត៖**

ទាយជ្ជទានសហព័ទ្ធ និងកូនក្នុងបន្ទុក = ១៥០,០០០៛ x សហព័ទ្ធ និងចំនួនកូនក្នុងបន្ទុក

មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) - ទាយជ្ជទានសហព័ទ្ធ និងកូនក្នុងបន្ទុក

ពន្ធលើប្រាក់បៀវត្ស (ពបវ) = (មពបវ x អត្រាពន្ធ) - លម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ (លបព)

**កំណត់សម្គាល់៖**

ចំពោះកម្មករនិយោជិត នៃរោងចក្រ សហគ្រាស ប្រសិនបើប្រាក់បៀវត្សជាប់ពន្ធ (បវ) មានរួមបញ្ចូលនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ប្រាក់ឧបត្ថម្ភនោះត្រូវបានអនុញ្ញាតឱ្យដកចេញពីប្រាក់បៀវត្សជាប់ពន្ធ (បវ)។

**ឧទាហរណ៍ទី១៖** កម្មករនិយោជិត នៃរោងចក្រ សហគ្រាស ម្នាក់មានប្រាក់បៀវត្ស ២,០០០,០០០ រៀល ដែលក្នុងនោះមានប្រាក់ឧបត្ថម្ភសោហ៊ុយធ្វើដំណើរ និងថ្លៃបាយសរុបចំនួន ២០០,០០០ រៀល។

**ក. ករណីនៅលីវ**

មពបវ = ២,០០០,០០០៛ - ២០០,០០០៛ = ១,៨០០,០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ៥%)

លបព = ៧៥,០០០៛ ពបវ = (១ ៨០០,០០០៛ X ៥%) - ៧៥,០០០៛ = ១៥,០០០៛

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣នាក់ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធ និងកូនក្នុងបន្ទុក = ១៥០,០០០៛ X ៤នាក់ = ៦០០,០០០៛

មពបវ = ២,០០០,០០០៛ - ២០០,០០០៛ - ៦០០,០០០៛ = ១,២០០,០០០៛ (ត្រូវជាប់ពន្ធតាមអត្រា 0%)

លបព = 0៛

ពបវ = (១,២០០,០០០៛ X 0%) - 0៛ = 0៛

**ឧទាហរណ៍ទី២៖** អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់មានប្រាក់បៀវត្ស ៩,០០០,០០០ រៀល។

**ក. ករណីនៅលីវ**

មពបវ = ៩,០០០,០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ១៥%)

លបព = ៦០០,០០០៛

ពបវ = (៩,០០០,០០០៛ X ១៥%) - ៦០០,០០០៛ = ៧៥០,០០០៛

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣នាក់ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធ និងកូនក្នុងបន្ទុក = ១៥០,០០០៛ X ៤នាក់ = ៦០០,០០០៛

មពបវ = ៩,០០០,០០០៛ - ៦០០,០០០៛ = ៨,៤០០,០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ១០%)

លបព = ១៧៥,០០០៛

ពបវ = (៨,៤០០,០០០៛ X ១០%) - ១៧៥,០០០៛ = ៦៦៥,០០០៛



## ៣.៣ ប្រាក់ពន្ធដែលប្រមូលបានពីពន្ធលើប្រាក់បៀវត្សបានផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ

### ៣.៣.១ អត្ថប្រយោជន៍ពីប្រាក់ពន្ធដែលប្រមូលបានពីពន្ធលើប្រាក់បៀវត្ស

ពន្ធលើប្រាក់បៀវត្សជាផ្នែកមួយនៃប្រាក់ចំណូលរបស់រដ្ឋដែល អាចប្រើប្រាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាកម្មសង្គមដូចជា សុខាភិបាល ការអប់រំ និងកម្រិតសេវាកម្មផ្សេងៗ។ ពន្ធដែលត្រូវបង់សម្រាប់ប្រាក់បៀវត្សនឹងជួយផ្គត់ផ្គង់សេវាកម្មសាធារណៈដូចជាសាលារៀន មន្ទីរពេទ្យ និងការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ ដែលចាំបាច់សម្រាប់ការរីកចម្រើនរបស់ប្រជាជន។ ពន្ធលើប្រាក់បៀវត្សអាចជួយកែសម្រួលវិធានការសង្គម ដើម្បីធានាបានថាពលរដ្ឋទាំងអស់មានភាពស្មោះត្រង់ក្នុងការទទួលយកសេវាកម្ម និងមានការចូលរួមក្នុងការអភិវឌ្ឍសង្គមយ៉ាងសមរម្យ។ ការបង់ពន្ធលើប្រាក់បៀវត្សជួយកាត់បន្ថយភាពខុសគ្នានៃចំណូលដោយការប្រមូលពន្ធពីមនុស្សដែលមានប្រាក់ចំណូលខ្ពស់ទៅឱ្យអ្នកដែលមានប្រាក់ចំណូលទាបជាមួយនឹងការផ្តល់អត្ថប្រយោជន៍សង្គមដូចជា បរិក្ខារជំនួយសង្គម ឬការកំណត់ជម្រើសក្នុងការចំណាយប្រាក់។ បន្ថែមពីនេះទៅទៀតនោះយើងឃើញថារដ្ឋក៏បានចំណាយជាច្រើនចំពោះសេដ្ឋកិច្ចប្រទេសជាតិជាច្រើនដូចជា:

- បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ មន្ត្រី កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តន៍ជន ។
- ពន្ធជាប្រភពចំណូលដ៏សំខាន់ដើម្បីទ្រទ្រង់ និងដំណើរការរដ្ឋទាំងមូល៖ ពន្ធដែលប្រមូលបានគឺសម្រាប់ចំណាយទៅលើ គ្រឿងឧបករណ៍ គ្រឿងសង្ហារឹម សម្ភារៈការិយាល័យនៅតាមក្រសួង មន្ទីរស្ថាប័ន និងអង្គភាពចំណុះឱ្យរដ្ឋ ។
- ប្រាក់ពន្ធដែលរដ្ឋប្រមូលបាន គឺសម្រាប់ចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធសង្គមដូចជា៖ ផ្លូវថ្នល់ស្ពាន សាលារៀន មន្ទីរពេទ្យជាដើម ។
- ចំណាយទៅលើវិស័យអប់រំ និងសុខាភិបាល៖ ការសិក្សា អប់រំចំណេះដឹងទូទៅដោយមិនបង់ប្រាក់តាមព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ ។
- ប្រាក់ពន្ធក៏ត្រូវបានចំណាយទៅលើវិស័យសន្តិសុខសណ្តាប់ធ្នាប់សង្គម និងវិស័យការពារជាតិ ។

ទោះបីជាមើលឃើញពីសារៈប្រយោជន៍របស់ពន្ធលើប្រាក់បៀវត្ស ក៏រដ្ឋបាលសារពើពន្ធមិនអាចប្រមូលប្រាក់ពន្ធបាន១០០% នៅឡើយទេដោយសារតែការយល់ដឹងពីកាតព្វកិច្ចរបស់បុគ្គលនៅកម្ពុជានៅមានកម្រិត។ ដូច្នេះហើយ អគ្គនាយកដ្ឋានពន្ធដារបានធ្វើទំនើបកម្មប្រព័ន្ធទិន្នន័យពន្ធដាររបស់ខ្លួនតាមបែបឌីជីថល ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកបង់ពន្ធនានា ក៏ដូចជាបញ្ជ្រាបពីកាតព្វកិច្ចរបស់បុគ្គលជាប់ពន្ធឱ្យបានទូលំទូលាយដើម្បីសម្រេចគោលដៅកំណើនប្រាក់ពន្ធ និងសមភាពកាតព្វកិច្ចពន្ធ តាមនិយាមអន្តរជាតិ។

សរុបមក ពន្ធលើប្រាក់បៀវត្សគឺ ជាឧបករណ៍សំខាន់សម្រាប់រដ្ឋក្នុងការអភិវឌ្ឍប្រទេស និងជានាពិធីការទៅរកសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។



ស្ពានអាកាសចោមចៅ




មន្ទីរពេទ្យ «តេជោសន្តិភាព»

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ជាធម្មតាការវិភាគចំណុចខ្លាំង និងចំណុចខ្សោយលើការអនុវត្តការងារ ឬច្បាប់ដែលបានកំណត់ តែងតែមាន។ ការវាយតម្លៃពិតជាមានសារៈសំខាន់ណាស់ ដើម្បីឱ្យយើងដឹងពីចំណុចខ្លាំង និងចំណុចខ្សោយកាន់តែច្បាស់លាស់ក្នុងការអនុវត្តជាក់ស្តែងក៏ដូចជាការគ្រប់គ្រងផងដែរ។ បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារ រួចមកក្រុមយើងខ្ញុំបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយ របស់អគ្គនាយកដ្ឋានពន្ធដារនៅពេលធ្វើវិសោធនកម្មមួយចំនួនដូចជា៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋាន ពន្ធដារ ក្រុមយើងខ្ញុំបានសង្កេតរកឃើញនូវចំណុចខ្លាំងមួយចំនួនដូចជា៖

- ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស បានជួយសម្រួលបន្ទុកដល់ជីវភាពរស់នៅប្រជាពលរដ្ឋឱ្យបានប្រសើរជាងមុន ព្រោះអត្រាកំណើនតាមថ្នាក់កាន់តែខ្ពស់ ជាហេតុនាំឱ្យបុគ្គលិកនិងកម្មករដែលមានប្រាក់បៀវត្សទាបបានរួចផុតពីការជាប់ពន្ធ
- ប្រាក់ពន្ធដែលប្រមូលបានជារៀងរាល់ខែបានរួមចំណែកយ៉ាងសំខាន់ក្នុងសកម្មភាពសេដ្ឋកិច្ចក៏ដូចជាសកម្មភាពក្នុងសង្គមដែលបានចូលរួមក្នុងការលើកស្ទួយនូវការអភិវឌ្ឍ ការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម (ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីពេទ្យ វត្តអារាម) ដែលធ្វើឱ្យប្រជាពលរដ្ឋងាយស្រួលក្នុង ការរស់នៅ និងការប្រកបអាជីវកម្មប្រចាំថ្ងៃជាដើម
- ការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ មន្ត្រីកម្លាំងប្រដាប់អាវុធ និងនិវត្តន៍ជន
- ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស ត្រូវអនុវត្តន៍តាមប្រកាសនិងបទបញ្ញត្តិដែលស្តីពីសារពើពន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានចេញផ្សាយ ដែលនាំឱ្យអ្នកជាប់ពន្ធងាយស្រួលក្នុងការត្រួតពិនិត្យ និងតាមដានទៅលើការកែប្រែ ដើម្បីអនុវត្តន៍តាមប្រកាសនិងបទបញ្ញត្តិដែលបានកែប្រែ
- ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស បានជួយលើកកម្ពស់ដល់សុខុមាលភាព និងកាត់បន្ថយការចំណាយយ៉ាងច្រើនដល់ប្រជាពលរដ្ឋ តាមរយៈការតំឡើងនូវកម្រិតកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះក្នុងម្នាក់ៗពី ៧៥,០០០រៀល (ច្បាប់ដែលបានចេញផ្សាយឆ្នាំ១៩៩៧) ដល់ ១៥០,០០០រៀល (ច្បាប់ចេញផ្សាយឆ្នាំ២០១៧) ក្នុងមួយខែ
- ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននូវសេដ្ឋកិច្ចកម្ពុជាដើម្បីធានាបាននូវប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

បន្ទាប់ពីបានរកឃើញនូវចំណុចខ្លាំងខាងលើរួចមក ក្រុមយើងខ្ញុំក៏ឃើញនូវចំណុចខ្វះខាតមួយចំនួន ដែលចាត់ទុកថាជាចំណុចខ្សោយ នៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរួមមាន៖

- ការទប់ស្កាត់នៃការគេចវេសពន្ធនៅមានកម្រិត
- អគ្គនាយកដ្ឋានពន្ធដារមិនបានកំណត់ពីរយៈពេលច្បាស់លាស់ក្នុងការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស
- អគ្គនាយកដ្ឋានពន្ធដារមិនបានផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ និងគោលបំណងនៃការធ្វើវិសោធនកម្មឱ្យបានទូលំទូលាយ
- ការកំណត់ឱ្យមានការបង់ពន្ធបានជះឥទ្ធិពលដល់អ្នកជាប់ពន្ធមួយចំនួន ឱ្យទទួលរងនូវការមិនពេញចិត្តក្នុងការបង់ពន្ធ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីប្រធានបទ ការនៃការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានពន្ធដារនៅកម្ពុជាកន្លងមក ក្រុមយើងខ្ញុំអាចធ្វើការកត់សម្គាល់បានថាអគ្គនាយកដ្ឋានពន្ធដារ បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការតាក់តែងច្បាប់ នីតិវិធីនៃការកំណត់ពន្ធ រយៈពេលនៃការបង់ពន្ធ ការគណនារកប្រាក់ពន្ធលើប្រាក់បៀវត្ស និងការអនុវត្តច្បាប់ពន្ធឱ្យបានត្រឹមត្រូវ ព្រមទាំងការធ្វើវិសោធនកម្ម ច្បាប់ពន្ធពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីកែប្រែច្បាប់ពន្ធឱ្យកាន់តែមានប្រសិទ្ធភាព សមស្របទៅតាមជីវភាពរបស់ប្រជាជនដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងនិវាសជន និងអនិវាសជន។

ម្យ៉ាងវិញទៀត រាល់ប្រាក់ចំណូលដែលពន្ធដារប្រមូលបាន គឺប្រើប្រាស់សម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ ដូចជា បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ បើកប្រាក់បៀវត្សជូនកងទ័ព និងកងកម្លាំងប្រដាប់អាវុធ សាងសង់ស្ពាន ផ្លូវថ្នល់ សាងសង់សាលារៀន សាងសង់មន្ទីរពេទ្យ ការពារព្រំដែន និងចំណាយទូទៅនានានៅក្នុងសង្គមកិច្ច សេដ្ឋកិច្ច និងការអភិវឌ្ឍ សមដូចពាក្យមួយឃ្លាពោលថា "**ការបង់ពន្ធជូនរដ្ឋ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីរួមចំណែកការពារ និងការអភិវឌ្ឍមាតុភូមិកម្ពុជា**"។

សរុបសេចក្តីមក ក្រុមយើងខ្ញុំអាចសន្និដ្ឋានបានថា ការធ្វើវិសោធនកម្មពិតជាបានរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឱ្យប្រទេសមានការអភិវឌ្ឍ ហើយក្រុមយើងខ្ញុំនឹងសង្ឃឹមយ៉ាងមុតមាំថា សាធារណជនទាំងអស់ជាពិសេស អ្នកជាប់ពន្ធ និងអ្នកមានកាតព្វកិច្ចជាអ្នកប្រមូលពន្ធ (សហគ្រាស រោងចក្រ សិប្បកម្ម) ងាកមកចាប់អារម្មណ៍ និងយកចិត្តទុកដាក់ទៅលើការបង់ពន្ធ ពីព្រោះវាជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសង្គមដែលត្រូវអនុវត្តជាចាំបាច់ ជាពិសេសពន្ធលើប្រាក់បៀវត្ស។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីបានពិភាក្សាទៅលើលទ្ធផលនៃការស្រាវជ្រាវរួចមក ក្រុមយើងខ្ញុំបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការកែលម្អនូវចំណុចខ្សោយឱ្យមានភាពល្អប្រសើរ ក្រុមនាងខ្ញុំសូមផ្តល់ជូនអនុសាសន៍មួយចំនួនដូចតទៅ៖

- ពង្រឹងច្បាប់ដើម្បីទប់ស្កាត់នៃការគេចវេសពន្ធ
- អគ្គនាយកដ្ឋានពន្ធដារគួរតែកំណត់កាលបរិច្ឆេទច្បាស់លាស់សម្រាប់ការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស ដើម្បីឱ្យអ្នកជាប់ពន្ធ និងភាគីពាក់ព័ន្ធអាចរៀបចំខ្លួនបានសមស្រប និងបង្កើនភាពជឿជាក់ចំពោះគោលនយោបាយពន្ធ
- អគ្គនាយកដ្ឋានពន្ធគួរតែពង្រឹងការផ្សព្វផ្សាយ អំពីអត្ថប្រយោជន៍ និងគោលបំណងនៃការធ្វើវិសោធនកម្មឱ្យបានទូលំទូលាយ ដើម្បីបង្កើនការយល់ដឹង និងការយល់ព្រមរបស់សាធារណជនឱ្យព្រមព្រៀងបង់ពន្ធដោយស្ម័គ្រចិត្ត
- គួរបន្តដំឡើងចំនួនទឹកប្រាក់ភាគបៀវត្សជាប់ពន្ធប្រចាំខែ ដើម្បីឱ្យបុគ្គលិកកម្មករនិយោជិតដែលមានប្រាក់បៀវត្សទាបបានរួចផុតពីពន្ធលើប្រាក់បៀវត្ស។

# ឯកសារយោង

# ឯកសារយោង


1. វិទ្យាស្ថានវ៉ាន់ដា. (២០២៤). *ច្បាប់ពន្ធដារកម្ពុជា.* បោះពុម្ពលើកទី១. ទំព័រទី២. ភ្នំពេញ។
2. វិទ្យាស្ថានវ៉ាន់ដា. (២០២២). *សៀវភៅគណនេយ្យអនុវត្តន៍ និងពន្ធ ក្រុមហ៊ុនសេវាកម្ម.* បោះពុម្ពលើកទី៣. ទំព័រទី២. ភ្នំពេញ។
3. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២០១៨). សារាចរណែនាំលេខ០០២ សហវ.អពដ. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨. *ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី*
4. វិទ្យាស្ថាន់ វ៉ាន់ដា. (២០២៤). *ច្បាប់ពន្ធដារកម្ពុជា.* បោះពុម្ពលើកទី១. ទំព័រទី៤. ភ្នំពេញ។
5. អគ្គនាយកដ្ឋានពន្ធដារ. (២០២២). *សទ្ទានុក្រមពន្ធដារ.* បោះពុម្ពលើកទី១ ទំព័រទី១៣២. ភ្នំពេញ។
6. លី ប៊ុណ្ណា. (២០២៤). *របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់* ទំព័រទី៥
7. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (២០២០). សារាចរណែនាំលេខ០០៦ សហវ.អពដ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០. *ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី*
8. អគ្គនាយកដ្ឋានពន្ធដា. (២០២២). *សទ្ទានុក្រមពន្ធដារ.* បោះពុម្ពលើកទី១. ទំព័រទី១៣៧. ភ្នំពេញ។
9. សាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា. រៀបរៀងដោយ វ៉ែន ឈុនហួត.*ពន្ធដារ.* ទំព័រទី១. ៩១ទំព័រ. Retrieved from https://chandaracitc.weebly.com/uploads/1/3/0/1/13016555/taxation.pdf (Accessed 13.03.25)
10. KHsearch. Lawyers. (2024, April 22). *តើវិសោធនកម្មសំដៅដល់អ្វី?* Retrieved from https://www.khsearch.com/qna/30966 (Accessed 13.03.25)
11. BiZKHMER. ប៉ុម ទូប. (2019, October 08). *តើពន្ធគឺជាអ្វី?* Retrieved from https://bizkhmer.com/articles/41290# (Accessed 12.03.25)
12. YouTube. Law Lyheng. (2020, December 23). *វិសោធនកម្ម.* Retrieved from https://www.youtube.com/watch?v=mo59-897_GE (Accessed 13.03.25)
13. Symmetry. (2017, September). *The History of Payroll Tax*. Retrieved from https://www.symmetry.com/payroll-tax-insights/the-history-of-payroll-tax (Accessed 15.03.25)
14. KHsearch. សេដ្ឋកិច្ច. (2019, January 09). *តើជាសេដ្ឋកិច្ចអ្វី?* Retrieved from https://www.khsearch.com/qna/13654 (Accessed 15.03.25)
15. Cameron, Rondo & Neal, Larry. (2015). *A Concise Economic History of the World: From Paleolithic Times to the Present.* Oxford University Press.
16. *General Department of Taxation.* (n.d.). *Tax on salary*. Ministry of Economy and Finance. (2023). *National budget la 2023.*https://www.tax.gov.kh/en/taxtypes/salary-tax https://www.mef.gov.kh/documents/national-budget-law-2023
17. International Monetary Fund. (2021). Cambodia: 2021 Article IV consultation—Press release; staff report; and statement by the executive director for Cambodia (IMF Country Report No. 21/115). https://www.imf.org/en/Publications/CR/Issues/2021/06/17/Cambodia-2021-Article-IV-Consultation-Press-Release-Staff-Report-and-Statement-by-the-460897
18. World Bank. (2022). Cambodia public expenditure review: *Strengthening public financial management for better outcomes*. Retrieved from https://documents.worldbank.org/en/publication/documents-reports/documentdetail/099315306152221057

# ឧបសម្ព័ន្ធ


អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
កំណែទម្រង់
ពន្ធដារកម្ពុជា
២០១៣-២០២០
និពន្ធដោយ
គង់ វិបុល
រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

បាត់ដំបង ភ្នំពេញ សៀមរាប

# វិទ្យាស្ថាន វ៉ាន់ដា

# VANDA INSTITUTE




# ច្បាប់ពន្ធដារកម្ពុជា

# Cambodia Taxation Law

Taxt Book/y1
VIA.PP/2024

រក្សាសិទ្ធិគ្រប់យ៉ាងដោយវិទ្យាស្ថាន វ៉ាន់ដា

បោះពុម្ពលើកទី១(២០២៤)

សម្រាប់ប្រើប្រាស់ផ្ទៃក្នុង

អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION

# សទ្ទានុក្រមពន្ធដារ

# TAX GLOSSARY

២០២២

22




# ទស្សនាវដ្ដីវិទ្យាសាស្ត្រ

# CIENCE MAGAZINE

លេខទី១ ២០២៣

71
ម. វិទ្យា ក់ន់ជា
A.PP 2023

# ក្រសួងអប់រំ យុវជន និងកីឡា

**MINISTRY OF EDUCATION YOUTH AND SPORTS**

# វិទ្យាស្ថាន វ៉ាន់ដា

**VANDA INSTITUTE**

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
# ជំនាញ សវនកម្ម

## ប្រធានបទ៖ ការប្រកាសពន្ធតែមប្រិ៍សារពើពន្ធរបស់ក្រុមហ៊ុន ក្នុងខណ្ឌ៧មករានៅទីចាត់ការពន្ធដារ រាជធានីភ្នំពេញ


រៀបរៀងដោយនិស្សិត៖ លី ប៊ុណ្ណា MA20/019

សាស្ត្រាចារ្យណែនាំ៖ បណ្ឌិត កង ឱម

បេក្ខបណ្ឌិត យ៉ាក ខុទ្ធី



015.1081
លី ប៊ុណ្ណា
VIA.PP/2024



ភ្នំពេញ-២០២៤

PHNOM PENH-2024

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី

អនុលោមតាមមាត្រា៤ នៃអនុក្រឹត្យលេខ ១៩៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ÷

### ១. រយៈពេលអនុវត្តនិងអត្រាកំណើនតាមថ្នាក់ថ្មី

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវអនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្ស ដែលបើកជូននិយោជិតចាប់ពី **ខែមករា ឆ្នាំ២០២៣ តរៀងទៅ** ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែនីមួយៗយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលប្រាក់បៀវត្សត្រូវបានបើក។

តារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម÷

| ភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0៛ | ដល់ | ១ ៥00 000៛ | 0% |
| ពី | ១ ៥00 00១៛ | ដល់ | ២ 000 000៛ | ៥% |
| ពី | ២ 000 00១៛ | ដល់ | ៨ ៥00 000៛ | ១0% |
| ពី | ៨ ៥00 00១៛ | ដល់ | ១២ ៥00 000៛ | ១៥% |
| | | លើសពី | ១២ ៥00 000៛ | ២0% |

### ២. ឧបត្ថម្ភធនសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក

ផ្អែកលើការបង្ហាញភ័ស្តុតាងនៃស្ថានភាពគ្រួសារ មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិតដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះ ក្នុងម្នាក់ៗ ១៥0 000 រៀល ក្នុងមួយខែ។ ការកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែទាប ដែលនាំឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សក្នុងរង្វង់ពី ១ ៥00 00១ រៀល ដល់ ២ 000 000 រៀល (ប្រមាណពី ៣៧៥ ទៅ ៥00 ដុល្លារអាមេរិក) អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

## ៣. ការគណនាពន្ធលើប្រាក់បៀវត្ស

យោងតាមមាត្រា៤២ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់បំប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។

ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសនជន ត្រូវកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស ដោយយកចំនួនប្រាក់បៀវត្សជាប់ពន្ធសរុប ដកចេញនូវទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក។ ដោយឡែក ចំពោះកម្មករនិយោជិត នៃរោងចក្រ សហគ្រាស ប្រាក់បៀវត្សជាប់ពន្ធ ត្រូវបានអនុញ្ញាតឱ្យដកចេញបន្ថែមទៀតនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ដូចមានចែងក្នុងសារាចរលេខ ០១១ សហវ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម។

បន្ទាប់មក ត្រូវពិនិត្យមើលថាតើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងថ្នាក់អត្រាពន្ធណាមួយ ទើបយកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើសប្រាក់ពន្ធសម្រាប់ថ្នាក់អត្រាពន្ធនោះ។ លម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១ ៥០០ ០០០ រៀល ដំបូង និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

តារាងអត្រាកំណើនតាមថ្នាក់និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ÷

| ភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ | លម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ៥០០ ០០០៛ | ០% | ០៛ |
| ពី | ១ ៥០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥% | ៧៥ ០០០៛ |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% | ១៧៥ ០០០៛ |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% | ៦០០ ០០០៛ |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០% | ១ ២២៥ ០០០៛ |

**រូបមន្ត÷**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x សហព័ទ្ធនិងចំនួនកូនក្នុងបន្ទុក

មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ (បវ) - ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក

ពន្ធលើប្រាក់បៀវត្ស (ពបវ) = (មពបវ x អត្រាពន្ធ) - លម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ (លបព)

<u>កំណត់សម្គាល់÷</u>

ចំពោះកម្មករនិយោជិត នៃរោងចក្រ សហគ្រាស ប្រសិនបើប្រាក់បៀវត្សជាប់ពន្ធ (បវ) មានរួមបញ្ចូលនូវប្រាក់ឧបត្ថម្ភដែលទទួលបានពីការបំពេញការងារ ប្រាក់ឧបត្ថម្ភនោះត្រូវបានអនុញ្ញាតឱ្យដកចេញពីប្រាក់បៀវត្សជាប់ពន្ធ (បវ)។

**ឧទាហរណ៍ទី១៖** កម្មករនិយោជិត នៃរោងចក្រ សហគ្រាស ម្នាក់មានប្រាក់បៀវត្ស ២ ០០០ ០០០ រៀល ដែលក្នុងនោះ មានប្រាក់ឧបត្ថម្ភសោហ៊ុយធ្វើដំណើរនិងថ្លៃបាយសរុបចំនួន ២០០ ០០០ រៀល។

**ក. ករណីនៅលីវ**

មពបវ = ២ ០០០ ០០០៛ - ២០០ ០០០៛ = ១ ៨០០ ០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ៥%)

លបព = ៧៥ ០០០៛

ពបវ = (១ ៨០០ ០០០៛ x ៥%) - ៧៥ ០០០៛ = ១៥ ០០០៛

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣នាក់ ក្នុងបន្ទុក**

ទាយជូនានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x ៤នាក់ = ៦០០ ០០០៛

មពបវ = ២ ០០០ ០០០៛ - ២០០ ០០០៛ - ៦០០ ០០០៛ = ១ ២០០ ០០០៛ (ត្រូវជាប់ពន្ធតាមអត្រា ០%)

លបព = ០៛

ពបវ = (១ ២០០ ០០០៛ x ០%) - ០៛ = ០៛

**ឧទាហរណ៍ទី២៖** អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់មានប្រាក់បៀវត្ស ៩ ០០០ ០០០ រៀល

**ក. ករណីនៅលីវ**

មពបវ = ៩ ០០០ ០០០៛ (ជាប់ពន្ធតាមអត្រា ១៥%)

លបព = ៦០០ ០០០៛

ពបវ = (៩ ០០០ ០០០៛ x ១៥%) - ៦០០ ០០០៛ = ៧៥០ ០០០៛

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣នាក់ ក្នុងបន្ទុក**

ទាយជូនានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x ៤នាក់ = ៦០០ ០០០៛

មពបវ = ៩ ០០០ ០០០៛ - ៦០០ ០០០៛ = ៨ ៤០០ ០០០៛ (ជាប់ពន្ធតាមអត្រា ១០%)

លបព = ១៧៥ ០០០៛

ពបវ = (៨ ៤០០ ០០០៛ x ១០%) - ១៧៥ ០០០៛ = ៦៦៥ ០០០៛

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ប្រាក់ពន្ធលើប្រាក់បៀវត្ស នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- រដ្ឋបាលរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ទម្រង់ ពបវ 01 (ស្នាក់ការកណ្តាល)
FORM TOS 01 (Head Office)

# លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស (ទីស្នាក់ការកណ្តាល)
## RETURN FOR TAX ON SALARY (HEAD OFFICE)

Reset form

ប្រចាំខែ Month M M ឆ្នាំ Year Y Y Y Y

### I. ព័ត៌មានសហគ្រាស / ENTERPRISE INFORMATION

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number (TIN) ☐☐☐☐ - ☐☐☐☐☐☐☐☐☐

### II. សរុបប្រាក់ពន្ធ / TOTAL AMOUNT OF TAX

| ល.រ No. | ប្រភេទពន្ធ Type of tax | ពន្ធត្រូវបង់ Tax payable |
|---|---|---|
| 09 | ពន្ធលើប្រាក់បៀវត្ស Tax on Salary | |
| 0២ | ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on Salary on Fringe Benefit | |

### III. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតនិវាសនជន / TAX ON SALARY FOR RESIDENT EMPLOYEES

| ល.រ No. | ចំនួននិយោជិត No. of employees | ប្រាក់បៀវត្សត្រូវបើក Salary to be paid | សហព័ទ្ធ Spouse | ចំនួនកូនក្មេងបន្ទុក No. of minor children | អត្រាពន្ធ Tax rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|---|---|
| 1 | | | | | 0% | |
| 2 | | | | | 5% | |
| 3 | | | | | 10% | |
| 4 | | | | | 15% | |
| 5 | | | | | 20% | |
| សរុប Total | | | | | | |

### IV. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតអនិវាសនជន / TAX ON SALARY FOR NON-RESIDENT EMPLOYEES

| ល.រ No. | ចំនួននិយោជិត No. of employees | ប្រាក់បៀវត្សត្រូវបើក Salary to be paid | អត្រាពន្ធ Tax rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|
| | A | B | C | D = B x C |
| 1 | | | 20% | |

### V. ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម / TAX ON SALARY ON FRINGE BENEFIT

| ល.រ No. | ចំនួននិយោជិត No. of employees | ប្រាក់អត្ថប្រយោជន៍បន្ថែម Fringe benefit | អត្រាពន្ធ Tax rate | ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on salary on Fringe benefit |
|---|---|---|---|---|
| | A | B | C | D = B x C |
| 1 | | | 20% | |

▶ តារាងលម្អិតអំពីពន្ធលើប្រាក់បៀវត្សចំពោះនិយោជិត និវាសនជន អនិវាសនជន និងពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម
Details of tax on salary for resident, Non-resident employees and Tax on Salary on Fringe benefit

**សម្គាល់ / Note1**

យើងខ្ញុំបានពិនិត្យគ្រប់ចំណុចទាំងអស់នៅលើលិខិតប្រកាសនេះ និងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ។ យើងខ្ញុំមានសក្ខីប័ត្របញ្ជាក់ច្បាស់លាស់ ត្រឹមត្រូវ ពេញលេញ ដែលធានាបានថា ព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះ ពិតជាត្រឹមត្រូវប្រាកដមែន ហើយគ្មានប្រតិបត្តិការណាមួយដែលមិនបានប្រកាសនោះទេ។ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ។ We have examined all items on this return and the annexes attached herewith. We have clear, correct, All supporting documents to ensure that all information on this return is true and accurate and there is no business operation undeclared. We are fully responsible due to the existing Laws for any falsified information.

